# សារាចរណែនាំស្តីពី
# ការអនុវត្តច្បាប់ហិរញ្ញវត្ថុ
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

តេលេក្រាម | ឯកសារមន្ត្រីសាធារណៈ

Scan to Join!

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០១៣ ......សហវ.......

ថ្ងៃ សុក្រ ៥រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០២១

# សារាចរណែនាំ

# ស្តីពី

# ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

## ១. សេចក្តីផ្តើម

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃ ពុធ ១១កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៥៣ អនក្រ.បក ចុះថ្ងៃ ពុធ ៣រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ និងអនុក្រឹត្យលេខ ២៥៤ អនក្រ.បក ចុះថ្ងៃ ពុធ ៣រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ។ ផ្អែកលើមូលដ្ឋាននៃច្បាប់ និងអនុក្រឹត្យខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៩៤០ សហវ.ប្រក ចុះថ្ងៃ ព្រហស្បតិ៍ ៤រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ និងប្រកាសលេខ ៩៤១ សហវ.ប្រក ចុះថ្ងៃ ព្រហស្បតិ៍ ៤រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ។

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ ដែលកម្ពុជាកំពុងស្ថិតក្នុងវិបត្តិជំងឺកូវីដ-១៩ នៅឡើយ បន្ទាប់ពី**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១** និងការបន្តរីករាលដាលនៃមេរោគកូរ៉ូណាបំប្លែងថ្មី ដែលបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់សុខភាព សង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងកំពុងដាក់សម្ពាធកាន់តែធ្ងន់មកលើថវិកាជាតិ ។ រាជរដ្ឋាភិបាលបាន និងកំពុងបញ្ចេញចំណាយអន្តរាគមន៍យ៉ាងច្រើន ដើម្បីទប់ទល់នឹងវិបត្តិនេះ ព្រមជាមួយនឹង

ការដាក់ចេញនូវ **"ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"** សំដៅលើកស្ទួយជីវភាពរបស់ប្រជាជនទូទៅ ។ ទន្ទឹមនេះ, ថវិកាឆ្នាំ ២០២២ ក៏ជាថវិកាឆ្នាំទី ៤ នៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ដែលតាមរយៈនេះ រាជរដ្ឋាភិបាលត្រូវបន្តខិតខំសម្រេចឱ្យបាននូវអាទិភាពគោលនយោបាយ និងគោលដៅអភិវឌ្ឍន៍សំខាន់ៗជាសារវន្ត, ដូចមានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤**, នៅលើមាគ៌ានៃការកែទម្រង់ស៊ីជម្រៅ និងការជំរុញការអភិវឌ្ឍ ដោយឈរលើមូលដ្ឋាននៃសមិទ្ធផលជាច្រើនដែលសម្រេចបានកន្លងមក, ទាំងខាងនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ពិសេសគឺ សន្តិភាព និងស្ថិរភាពនយោបាយដ៏រឹងមាំជាប់មិនដាច់ ដែលជាមូលដ្ឋានគ្រឹះដ៏ចម្បងបំផុត និងមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍជាតិ និងភាពសុខក្សេមក្សាន្តរបស់ប្រជាជន ។ មួយវិញទៀត, ថវិកាឆ្នាំ ២០២២ ក៏ជាថវិកា ដែលត្រូវធានាជោគជ័យនៃការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងជោគជ័យនៃការបំពេញកាតព្វកិច្ចតំបន់ និងអន្តរជាតិរបស់កម្ពុជា ពិសេសគឺ ការធ្វើជាម្ចាស់ផ្ទះ និងជាប្រធានអាស៊ាន នៅឆ្នាំ ២០២២ ។

ដើម្បីសម្រេចគោលដៅនេះ, ថវិកាឆ្នាំ ២០២២ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **អភិក្រមគ្រឹះ** ជាយុទ្ធសាស្ត្រសំខាន់ចំនួន ៥ រួមមាន÷ (១)-ទប់ទល់ការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងរស់នៅជាមួយជំងឺកូវីដ-១៩ នៅក្នុងគន្លងប្រក្រតីថ្មី; (២)-អនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៤,៨% និងបន្តបង្កើតការងារជូនប្រជាជន ជាពិសេសស្រទាប់យុវជនផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញ និងបង្កើនចំណូលថវិកាជាតិ; (៣)-ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាពិសេសការគ្រប់គ្រងបាននូវអតិផរណា និងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ; (៤)-បន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច សំដៅធានាស្ថិរភាពកំណើន គាំទ្រដល់ការស្តារសេដ្ឋកិច្ចនិងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជនតាមការសន្យា ព្រមទាំងពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និងសមត្ថភាពនៃវិស័យសាធារណៈ ក្នុងគោលដៅពង្រីកវិសាលភាព និងពង្រឹងគុណភាពនៃសេវាសាធារណៈ និងសេវាយុត្តិធម៌; និង (៥)-ធានាអនុវត្តឱ្យបានជោគជ័យនូវរបៀបវារៈនៃការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ពិសេសការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏ដូចជាការបំពេញកាតព្វកិច្ចតំបន់ និងអន្តរជាតិរបស់កម្ពុជា ពិសេសក្នុងនាមជាប្រធានអាស៊ាន ។

ផ្អែកលើអភិក្រមគ្រឹះជាយុទ្ធសាស្ត្រខាងលើ ថវិកាឆ្នាំ ២០២២ ត្រូវបានរៀបចំឡើង ដោយឈរលើ **គោលការណ៍បច្ចេកទេសសំខាន់ៗ** ចំនួន ៧ ទៀត រួមមាន÷

***១-ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល*** ក្នុងបរិការណ៍ដែលចំណូលក្នុងប្រទេសមាននិន្នាការថយចុះដោយសារផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដែលទទួលបន្ទុកកៀរគរចំណូលមិនមែនសារពើពន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកកៀរគរចំណូលសារពើពន្ធ ចាំបាច់



ឯកសារមន្ត្រីរាជការណ៍ | https://t.me/oa_channel

ត្រូវបន្តរក្សាចលនការនៃការខិតខំប្រឹងប្រែងក្នុងការកៀរគរចំណូលថវិកាឱ្យអស់លទ្ធភាព ជាពិសេសពង្រឹងមន្ត្រីមានសមត្ថកិច្ច ក៏ដូចជាអង្គភាពពាក់ព័ន្ធនឹងការប្រមូលចំណូលរបស់ខ្លួនមិនឱ្យធ្លាក់ដៃក្នុងការបំពេញភារកិច្ច ទន្ទឹមនឹងការបន្តរក្សានូវភាពប្រយ័ត្នប្រយែង ព្រមទាំងការពង្រឹងអភិបាលកិច្ច និងយុត្តិធម៌ក្នុងការផ្តល់សេវា និងការប្រមូលពន្ធដារ ។

*២-ការធ្វើវិចារណកម្មលំដាប់អាទិភាព* តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ ជាពិសេសលើកម្មវិធី/ សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង- ស្ថាប័ន ក្នុងក្របខ័ណ្ឌនៃរក្សាលំនឹងជីវភាព សង្គម និងសេដ្ឋកិច្ច ព្រមទាំងការត្រៀមលក្ខណៈដើម្បីស្តារសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ក្នុងន័យនេះ វិធានការបច្ចេកទេសលម្អិតចំនួន ៤ ទៀត ត្រូវបានបន្តអនុវត្ត រួមមាន÷ *(១)-មិនផ្តល់ថវិកាសម្រាប់មុខចំណាយមិនចាំបាច់ និងចំណាយលែងចាំបាច់, (២)-រឹតបន្តឹងខ្លាំងក្នុងការផ្តល់ថវិកាសម្រាប់មុខចំណាយមិនសូវចាំបាច់, (៣)-បន្តផ្តល់ថវិកាចំពោះមុខចំណាយដែលចាំបាច់, និង (៤)-ហ៊ានចាយបន្ថែមលើមុខចំណាយដែលចាំបាច់ខ្លាំង ។*

*៣-ការយកចិត្តទុកដាក់លើមនុស្ស* ដោយរក្សាកម្រិតប្រាក់បៀវត្សអប្បបរមាជូនមន្ត្រីរាជការគ្រប់ប្រភេទ ព្រមទាំង របបតាវកាលិកចាំបាច់ផ្សេងៗ និងការគាំពារសង្គមផ្សេងៗទៀត ស្មើនឹងកម្រិតឆ្នាំ ២០២១ ប៉ុន្តែបន្តផ្តល់អាទិភាពដល់ការកសាង និងពង្រឹងធនធានមនុស្ស និងផ្តល់ការយកចិត្តទុកដាក់ដល់ការឧបត្ថម្ភគាំទ្រចំពោះមនុស្សដែលត្រូវទទួលខុសត្រូវក្នុងការអនុវត្តការងារផ្ទាល់លើការផ្តល់សេវាសាធារណៈ ព្រមទាំងការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងកម្មវិធីសាច់ប្រាក់ពលកម្ម ។

*៤-កំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព* តាមរយៈការបន្តគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ, បរិមាណ, និងគុណភាព ក្នុងការអនុវត្តកម្មវិធី/ សកម្មភាព ក្នុងគោលដៅជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា ។

*៥-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត* តាមរយៈការជំរុញ និងបង្កើនការផ្ទេរថវិកាឱ្យទៅដល់អង្គភាពអនុវត្តការងារផ្ទាល់ ដែលនៅក្រោមឱវាទក្រសួង- ស្ថាប័ននៅរដ្ឋបាលកណ្តាល ឬនៅតាមមូលដ្ឋាន ជាពិសេសតាមសាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព ទន្ទឹមនឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការទទួលខុសត្រូវនៅនឹងកន្លែង ។

*៦-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា* ដោយផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពចំណាយមិនមែនបុគ្គលិកដល់ក្រសួង- ស្ថាប័នដែលកៀរគរចំណូលបានដោយការខិតខំធ្វើសកម្មភាពរបស់ខ្លួនផ្ទាល់ ។

*៧-ការរក្សាតុល្យភាព និងចីរភាពថវិកា÷* រក្សាតុល្យភាពនៃតម្រូវការបន្ទាន់ ជាមួយតម្រូវការនិងហានិភ័យរយៈពេលមធ្យម ក្រោមសម្ពាធនៃការធ្លាក់ចុះយ៉ាងគំហុកនៃចំណូល ស្របពេលដែលតម្រូវការចំណាយដែលចេះតែកើនឡើង, ទាំងចំណាយចរន្ត និងចំណាយវិនិយោគសាធារណៈ, ដែលចាំបាច់សម្រាប់ជំរុញកំណើន និងលើកស្ទួយភាពប្រកួតប្រជែង ព្រមទាំងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន, គម្រោងថវិកា

ឆ្នាំ ២០២២ នៅតែត្រូវបានរៀបចំដោយឆ្លើយតបបានទាំងស្រុងទៅនឹងគោលដៅរក្សាលំនឹងជីវភាព សង្គម សេដ្ឋកិច្ច ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងត្រៀមខ្លួនដើម្បីស្តារកំណើនសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ក្រោយវិបត្តិជំងឺកូវីដ-១៩ ។

ដូចនេះ ក្នុងក្របខ័ណ្ឌនៃកំណើនសេដ្ឋកិច្ច ដែលត្រូវបានគ្រោងក្នុងរង្វង់ ៤,៨% និងក្នុងគោលដៅបន្តបម្រើឱ្យបណ្តាអាទិភាពនៃ "យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤" នៅក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ បានកំណត់ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ ដូចតទៅ÷

- ចំណាយសរុបនៃថវិការដ្ឋស្មើនឹង ២៧,៩៥% នៃ ផ.ស.ស.,
- ចំណូលក្នុងប្រទេសថវិការដ្ឋត្រូវសម្រេចឱ្យបានស្មើនឹង ២០,៦១% នៃ ផ.ស.ស.,
- អតិរេកចរន្តត្រូវរក្សាឱ្យបានក្នុងកម្រិតប្រមាណ ២,៧៧% នៃ ផ.ស.ស.,
- ឱនភាពថវិកាជាតិសរុបនឹងមានទំហំស្មើនឹង -៧,៣៤% នៃ ផ.ស.ស. ដែលត្រូវបានបំពេញតុល្យភាពដោយ÷ **(១)-ហិរញ្ញប្បទានក្រៅប្រទេស** ក្នុងទំហំ **៤,៦៨%** នៃ ផសស; **(២)-មូលនិធិទ្រទ្រង់ថវិកា** ក្នុងទំហំ **១,០២%** នៃ ផសស; **(៣)-ការបោះផ្សាយលក់មូលបត្ររដ្ឋ** ក្នុងទំហំ ០.៩៨% នៃ ផសស ស្មើនឹង **១ ២១៩ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៣០០ លានដុល្លារអាម៉េរិក**; និង **(៤)**-ប្រាក់បញ្ញើរាជរដ្ឋាភិបាល ក្នុងទំហំ **១,៦៥%** នៃ ផសស ស្មើនឹង **២ ០៣២ ប៊ីលានរៀល**, សមមូលនឹង **៥០០ លានដុល្លារអាម៉េរិក** ដែលត្រូវបានគ្រោងយកមកប្រើប្រាស់សម្រាប់អនុវត្តគោលនយោបាយ និងវិធានការរក្សាលំនឹងទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ជាពិសេសសម្រាប់អនុវត្ត **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី** ។

ដូចនេះ ដើម្បីឱ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ សម្រេចបានតាមគោលដៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើ**ការអនុវត្តថវិកាថ្នាក់ជាតិ**សម្រាប់ឆ្នាំ ២០២២ ដូចខាងក្រោម÷

## ២. លក្ខខណ្ឌ និងវិធានការក្នុងការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ ២០២២

### ២.១-ការរៀបចំ និងការអនុវត្តកម្មវិធីចំណូល-ចំណាយ

ដើម្បីឱ្យការអនុវត្តថវិកាមានភាពជឿទុកចិត្តបាន និងប្រព្រឹត្តទៅដោយរលូន ជាពិសេសដើម្បីធានាការឆ្លើយតបនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលា គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវពង្រឹងភាពជាម្ចាស់ក្នុងការរៀបចំគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសម្រាប់រយៈពេលពេញមួយឆ្នាំ ដែលមានបែងចែកលម្អិតទៅតាមខែ និងទៅតាមគំរូដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃតម្រូវការចំណាយជាក់ស្តែង ទៅតាមប្រតិទិននៃផែនការសកម្មភាពការងារ និងផែនការលទ្ធកម្ម និងក្នុងក្របខ័ណ្ឌនៃឥណទានថវិកាដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ។ ក្រសួង-ស្ថាប័នត្រូវផ្ញើកម្មវិធីចំណូល-ចំណាយ ដែល

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

បានរៀបចំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា), ដោយឡែក មន្ទីរជំនាញរាជធានី-ខេត្ត ក្រោមឱវាទទាំងអស់ ត្រូវផ្ញើកម្មវិធីចំណូល (ចំណូលពីទ្រព្យសម្បត្តិរដ្ឋ) និងកម្មវិធីចំណាយដែលបានរៀបចំទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយច្បាប់ ដើម្បីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) និងទៅក្រសួង-ស្ថាប័នដែលជាខ្សែបណ្ដោយរបស់ខ្លួនមួយច្បាប់ សម្រាប់ការគ្រប់គ្រង និងតាមដានការអនុវត្ត ។ ក្រោយពីទទួលបានកម្មវិធីចំណូល-ចំណាយ ដែលស្នើឡើងដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវាយតម្លៃលើអាទិភាពនៃតម្រូវការ និងលទ្ធភាពចំណូលដែលអាចប្រមូលបាន ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ទៅតាមមាតិកាថវិកាសម្រាប់អនុវត្ត ។

ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសឱ្យកាន់តែបានត្រឹមត្រូវ និងសុក្រឹត ព្រមទាំងការអនុវត្តឱ្យបានម៉ឺងម៉ាត់តាមកម្មវិធីចំណូល-ចំណាយនេះ គឺជាប្រការចាំបាច់បំផុត ។ ដូច្នេះ គ្រប់ក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ អគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវអភិក្រមការងារ ដូចខាងក្រោម÷

### ២.១.១- ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស

• អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនូវរបាយការណ៍ប៉ាន់ស្មានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ដែលកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្ដែងប្រចាំខែទី ១ និងខែទី ២ និងការប៉ាន់ស្មានការអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ *នៅរៀងរាល់ថ្ងៃទី ២០ នៃខែ នាចុងត្រីមាសនីមួយៗ* ។

• មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្ត ដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្ដែងប្រចាំខែទី ១ និងខែទី ២ និងការប៉ាន់ស្មានអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១៥ នៃខែ នាចុងត្រីមាសនីមួយៗ ដើម្បីទុកពេលវេលាឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បូកសរុបរួចផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *ឱ្យបានមុនថ្ងៃទី ២០ នៃខែ នាចុងត្រីមាសនីមួយៗ* ។

• អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចរៀបចំប្រជុំពិភាក្សាតាមការចាំបាច់ជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់ *នៅរៀងរាល់ថ្ងៃទី ២៥ នៃខែ នាចុងត្រីមាសនីមួយៗ* ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ត្រូវរៀបចំប្រកាសកម្មវិធីចំណូល-ចំណាយ

សម្រាប់ត្រីមាសបន្ទាប់ ទៅតាមមាតិកាថវិកាក្នុងកម្រិតឥណទានថវិកាអតិបរមាសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទនីមួយៗ ដោយចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ ។

**២.១.២-ការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស**

អាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយអគ្គនាយកដ្ឋានថវិកា, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី-ខេត្ត ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និងត្រូវពិនិត្យ ទូទាត់ និងបើកសាច់ប្រាក់ តែនៅក្នុងកម្រិតនៃកម្មវិធីចំណូល-ចំណាយថវិកា និងសាច់ប្រាក់ប្រចាំត្រីមាសនេះតែប៉ុណ្ណោះ ។ ក្នុងករណីដែលអាណត្តិបើកប្រាក់លើសពីរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាស, ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវធ្វើសំណើសុំបន្ថែមកម្មវិធីចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**២.១.៣-ការតាមដានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស**

- អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រសួង-ស្ថាប័នទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវផ្ញើរបាយការណ៍អនុវត្តចំណូល-ចំណាយប្រចាំខែ មកអគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់* ។
- អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបញ្ជូនមកឱ្យអគ្គនាយកដ្ឋានថវិកានូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ និងរបាយការណ៍បុរេប្រទានប្រចាំខែ និងត្រូវបញ្ជូនមកឱ្យអគ្គនាយកដ្ឋានគោលនយោបាយនូវរបាយការណ៍ចំណូល-ចំណាយថវិកា, របាយការណ៍បុរេប្រទាន និងតារាងតុល្យភាពគណនីថវិកាប្រចាំខែ ដើម្បីឱ្យអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយ តាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ, ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន និងវាយតម្លៃនូវស្ថានភាពនៃអនុវត្តធៀបនឹងខែមុន, ត្រីមាសមុននៃឆ្នាំនេះ និងប្រៀបធៀបទៅនឹងខែ, ត្រីមាសដូចគ្នានៃឆ្នាំមុន *ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់* ។

**២.២-ការអនុវត្តការប្រមូលចំណូលថវិកា**

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យស្មើនឹង ១៨,៩០% នៃ ផ.ស.ស. គឺស្មើនឹង ២៣ ៤៦២,៦ ប៊ីលានរៀល ដែលកើនឡើង ១៧,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។ តាមគោលដៅនេះ÷

**២.២.១-ចំណូលចរន្តថ្នាក់ជាតិ** ត្រូវសម្រេចឱ្យបានចំនួន ២២ ១៥៧,៣ ប៊ីលានរៀល ត្រូវជា ១៧,៨៥% នៃ ផ.ស.ស. គឺមានការកើនឡើង ១២,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដែលក្នុងនោះ÷

❖ **ចំណូលសារពើពន្ធ** ត្រូវសម្រេចឱ្យបានចំនួន ២០ ២២៧ ប៊ីលានរៀល ត្រូវជា ១៦,២៩% នៃ ផ.ស.ស. គឺមានកើនឡើង ១៥,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷

- ចំណូលគយនិងរដ្ឋាករ ត្រូវបានគ្រោងចំនួន ១០ ៤០០ ប៊ីលានរៀល ត្រូវជា ៨,៣៨% នៃ ផ.ស.ស. គឺមានការកើនឡើង ៩,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១



ឯកសារមន្ត្រីរាជការ | https://t.me/oa_channel

- ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន ៩ ៨២៧ ប៊ីលានរៀល ត្រូវជា ៧,៩១% នៃ ផ.ស.ស. គឺមានការកើនឡើង ២២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងពេលដែលនៅឆ្នាំ ២០២២ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មី ឬបង្កើនអត្រាពន្ធនោះទេ ។

❖ **ចំណូលមិនមែនសារពើពន្ធ** ត្រូវបានគ្រោងចំនួន ១ ៩៣០,៣ ប៊ីលានរៀល ត្រូវជា ១,៥៥% នៃ ផ.ស.ស. គឺមានការថយចុះ ១១,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷

- ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតនៅថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន ១ ៧៥៦,២ ប៊ីលានរៀល ថយចុះ ៩,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១,
- ចំណូលពាក់ព័ន្ធនឹងកាតព្វកិច្ចពីកាស៊ីណូ ឆ្នោត អាជ្ញាប័ណ្ណ ត្រូវបានគ្រោងចំនួន ១៧៤,២ ប៊ីលានរៀល ថយចុះ ២៩,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។

**២.២.២-ចំណូលមូលធន** ត្រូវបានគ្រោងចំនួន ៨ ៣៨៧ ប៊ីលានរៀល ត្រូវជា ៦,៧៥% នៃ ផ.ស.ស. គឺមានកំណើន ២៨,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដែលក្នុងនោះ÷

❖ **ចំណូលមូលធនក្នុងប្រទេស** ដែលជាចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមពីសហគ្រាសសាធារណៈរបស់រដ្ឋ និងការបោះផ្សាយលក់មូលបត្ររដ្ឋ ត្រូវសម្រេចឱ្យបានចំនួន ១ ៣០៥,៣ ប៊ីលានរៀល ត្រូវជា ១,០៥% នៃ ផ.ស.ស. គឺមានកំណើន ៤៩០,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២១ ។

❖ **ចំណូលមូលធនក្រៅប្រទេស** ត្រូវសម្រេចឱ្យបានចំនួន ៧ ០៨១,៨ ប៊ីលានរៀល ត្រូវជា ៥,៧០% នៃ ផ.ស.ស. គឺមានកំណើន ១២,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ÷

- មូលនិធិទ្រទ្រង់ថវិកា ត្រូវបានគ្រោងចំនួន ១ ២៦៨,៣ ប៊ីលានរៀល ត្រូវជា ១,០២%នៃ ផ.ស.ស. គឺមានកំណើន ៤៧,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១
- ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់គម្រោងវិនិយោគ ដែលមានប្រភពពីហិរញ្ញប្បទានឥតសំណង និងពីការខ្ចី ត្រូវបានគ្រោងចំនួន ៥ ៨១៣,៥ ប៊ីលានរៀល ត្រូវជា ៤,៦៨% នៃ ផ.ស.ស. គឺមានការកើនឡើង ៦,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។

ដើម្បីសម្រេចបានតាមគោលដៅខាងលើ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវរៀបចំអនុវត្ត និងតាមដានជាប្រចាំ នូវកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលម្អិតទៅតាមខែ ។ បើគិតជាមធ្យមភាគប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារមានកាតព្វកិច្ចប្រមូលចំណូលពន្ធដែលជាចំណូលថវិកាថ្នាក់ជាតិឱ្យបានជាមធ្យមចំនួនប្រមាណ **៨១៨ ៩១៧ លានរៀល** ក្នុងមួយខែ ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានកាតព្វកិច្ចប្រមូលចំណូលពន្ធ និងអាករ ដែលជាចំណូលថវិកាថ្នាក់ជាតិឱ្យបានជាមធ្យមចំនួនប្រមាណ **៨៦៦ ៦៦៧ លានរៀល** ក្នុងមួយខែ ។ ដោយឡែក ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិត្រូវប្រមូលឱ្យបានជាមធ្យមចំនួនប្រមាណ **១៦០ ៨៦២ លានរៀល** ក្នុងមួយខែ ។ ទន្ទឹមនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលម្អិត និងតាមប្រភេទនិងមាតិកាចំណូលនីមួយៗ ហើយប្រគល់ឱ្យតាមសាខា, ទីស្នាក់ការ ឬ/និងមន្ត្រីដែលមានកាតព្វកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត ដោយ

ផ្អែកលើកិច្ចសន្យាផ្ទុលទ្រព្យសម្បត្តិរដ្ឋ, កិច្ចសន្យាសម្បទាននានា, ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និងសង្វាក់នៃការប្រមូលចំណូលកន្លងមក ។ អង្គភាពប្រមូលចំណូលត្រូវតាមដាន និងជំរុញជាប្រចាំនូវការអនុវត្តកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និងរិះរកវិធានការឱ្យបានទាន់ពេលវេលាក្នុងករណីពិនិត្យឃើញថា ការប្រមូលចំណូលសម្រេចបានលទ្ធផលទាបជាងកម្មវិធីកំណត់ ។

**២.៣-វិធានការអនុវត្តការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

សម្រាប់ក្នុងរយៈពេលបន្ទាន់ និងចំពោះមុខនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ រួមទាំងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ ដើម្បីសម្រេចឱ្យបានតាមគោលដៅដែលបានគ្រោងទុក តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ ដូចខាងក្រោម÷

**២.៣.១-ផ្នែកចំណូលគយ និងរដ្ឋាករ÷** ដើម្បីសម្រេចបានតាមផែនការចំណូលដែលបានកំណត់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងដាក់ចេញវិធានមួយចំនួន ដូចខាងក្រោម÷

- **ការបន្តពង្រឹងការងារបច្ចេកទេសគយ និងប្រសិទ្ធភាពនៃការប្រមូលចំណូល រួមមាន÷**
  - បន្តពង្រឹងការអនុវត្តយន្តការវាយតម្លៃហានិភ័យលើធុរជននិងទំនិញ ក្នុងការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ការធ្វើចំណាត់ថ្នាក់ទំនិញ និងការផ្ទៀងផ្ទាត់ដើមកំណើតទំនិញ,
  - បន្តជំរុញការអនុវត្តវិធានបញ្ជាក់ជាមុន (Advance Ruling),
  - បន្តពិនិត្យមុខសញ្ញាទំនិញដែលមានហានិភ័យ ដោយត្រូវកំណត់មាត់ច្រកនាំចូល,
  - លើកកម្ពស់ការយល់ដឹងរបស់ធុរជនលើការងារបច្ចេកទេសគយ និងនីតិវិធីនៃការបំពេញបែបបទគយតាមរយៈការផ្សព្វផ្សាយមគ្គុទ្ទេសក៍ និងវគ្គបណ្តុះបណ្តាលអំពីតម្លៃគិតពន្ធគយ ចំណាត់ថ្នាក់ទំនិញ និងការអនុវត្តអត្រាពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ព្រមទាំងនីតិវិធីគយជាធរមាន,
  - ពង្រឹងបន្ថែមក្នុងការអនុវត្តការងារបច្ចេកទេសគយដល់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចពាក់ព័ន្ធនឹងការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ការធ្វើចំណាត់ថ្នាក់ទំនិញ និងការផ្ទៀងផ្ទាត់ដើមកំណើតទំនិញ ។
- **ការបន្តពង្រឹងរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម រួមមាន÷**
  - បន្តធ្វើសាមញ្ញកម្មនីតិវិធីគយ និងជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងកិច្ចប្រតិបត្តិការគយ,
  - បន្តធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានាឱ្យបានកាន់តែទូលាយ ដូចជាប្រព័ន្ធអាស៊ីគូដា, ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធបញ្ចរតែមួយជាតិជាដើម,
  - បន្តធ្វើសន្ធានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយជាមួយភាគីពាក់ព័ន្ធផ្សេងៗទៀត,
  - បន្តអនុវត្តយន្តការលើកទឹកចិត្តដល់ធុរជនមានអនុលោមភាពខ្ពស់ តាមរយៈការផ្តល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងបន្តពិនិត្យលទ្ធភាពបង្កើនចំនួនធុរជនល្អបំផុត,



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- បន្តពង្រឹងប្រសិទ្ធភាពនៃការបង្ការ និងបង្ក្រាបបទល្មើសគយ តាមរយៈការចុះឃ្លាំមើលតំបន់ភូមិសាស្ត្រដែលមានហានិភ័យខ្ពស់, ការវិភាគព័ត៌មានសម្ងាត់និងកម្រិតហានិភ័យ និងការចែករំលែកព័ត៌មានសម្ងាត់,
- ពង្រឹងអនុលោមភាពនៃការអនុវត្តនីតិវិធីដឹកជញ្ជូនទំនិញ និងការគ្រប់គ្រងស្តុកទំនិញនៅតាមបណ្តាមាត់ច្រកនាំចូល,
- បន្តពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធនិងអាករ និងបន្តធ្វើវិចារណកម្មលើមុខទំនិញដែលទទួលបានគោលការណ៍លើកទឹកចិត្ត,
- បន្តកែលម្អប្រសិទ្ធភាពការងារគ្រប់គ្រងហានិភ័យ,
- បន្តពង្រឹងយន្តការនិងពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ,
- តាមដាន និងជំរុញការអនុវត្តបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជរបស់ WTO,
- ពង្រឹងការត្រួតពិនិត្យលើការបំពេញបែបបទបញ្ចេញទំនិញពីគយលើមុខទំនិញរបស់ក្រុមហ៊ុនដែលនាំចេញនាំចូលមិនស្របតាមសកម្មភាពចម្បងនៃអាជីវកម្មរបស់ខ្លួន,
- ពង្រឹងការត្រួតពិនិត្យរូបវ័ន្តទំនិញ តាមគោលការណ៍គ្រប់គ្រងហានិភ័យ,
- ជំរុញការអនុវត្តនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-Arrival Processing),
- បន្តជំរុញនិងពង្រីកការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ។

❖ **ការបន្តពង្រឹងគោលនយោបាយពន្ធគយ និងអភិបាលកិច្ច÷**

- បន្តធ្វើការវាយតម្លៃផលប៉ះពាល់លើចំណូលពន្ធអាករគយដែលបាត់បង់ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា និងការកើនឡើងនូវផលិតផលក្នុងស្រុកជំនួសការនាំចូលជាដើម,
- ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលក្នុងករណីចាំបាច់,
- កែលម្អគោលនយោបាយពន្ធនិងអាករ សម្រាប់វិស័យអាទិភាពនានា,
- កែលម្អគោលនយោបាយពន្ធនិងអាករលើមុខទំនិញគេលសិលា និងថាមពល ស្របតាមតម្រូវការចាំបាច់ និងការវិវត្តមុខទំនិញទាំងនេះ,
- បន្តចូលរួមកែលម្អ និងអនុវត្តគោលនយោបាយលើកទឹកចិត្តវិស័យអាទិភាព ដូចជាវិស័យកសិកម្ម, កម្មន្តសាល និងសហគ្រាសធុនតូចនិងមធ្យម,
- ពង្រឹងការងារសវនកម្មផ្ទៃក្នុង ដើម្បីធានានូវការអនុវត្តការងារប្រកបដោយការទទួលខុសត្រូវ និងអនុលោមភាពច្បាប់ ។

**២.៣.២-ផ្នែកចំណូលពន្ធដារ÷** ដើម្បីសម្រេចបានតាមផែនការចំណូលដែលបានកំណត់ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងអនុវត្តវិធានការមុតស្រួច ដូចខាងក្រោម÷

❖ វិធានការគោលនយោបាយ

- បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីបង្កើនការប្រមូលចំណូលពន្ធ,
- បន្តរៀបចំយន្តការសំខាន់ៗសម្រាប់ពង្រឹងការអនុវត្តតារាងឧបសម្ព័ន្ធតម្លៃអចលនទ្រព្យថ្មីសម្រាប់មូលដ្ឋានគិតពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ និងតម្លៃមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ,
- កែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការស៊ើបអង្កេតបទល្មើសពន្ធដារ,
- តាមដាន វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ,
- បន្តតាមដាន វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍លើការអនុវត្តគោលនយោបាយពន្ធដារកម្ពុជា,
- បន្តចរចាជាមួយបណ្តាប្រទេសនានា ព្រមទាំងរដ្ឋសមាជិកអាស៊ាន, អាស៊ានបូក ៣ ដែលនៅសេសសល់ លើការងារកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) ដើម្បីជំរុញកំណើនវិនិយោគពីបរទេស និងបង្កើនមូលដ្ឋានពន្ធ,
- ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- ពិនិត្យលទ្ធភាពលើការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅទីប្រជុំជន,
- ពិនិត្យឡើងវិញការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ ។

❖ វិធានការរដ្ឋបាលសារពើពន្ធ

(១). ការចុះបញ្ជីអ្នកជាប់ពន្ធ

- បន្តពង្រឹងការប្រមូលផ្តុំព័ត៌មានអចលនទ្រព្យ តាមរយៈការចុះផ្តល់សេវាពន្ធដារលើការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យដល់ទីកន្លែងនៅតាមបណ្តាខេត្ត,
- បន្តជំរុញការចុះបញ្ជីចំពោះសហគ្រាសថ្មីៗ ដើម្បីបង្កើនមូលដ្ឋានអ្នកជាប់ពន្ធ (Tax Base),
- រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យចុះបញ្ជីពន្ធដារ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងការចុះបញ្ជីពន្ធដារ,
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុលពន្ធ ដើម្បីសម្រួលដល់ការចុះបញ្ជីពន្ធដាររបស់អ្នកជាប់ពន្ធ,
- ជំរុញការចុះបញ្ជីសហគ្រាសឱ្យបាន ២០% ក្នុងមួយឆ្នាំ ធៀបនឹងចំនួនសហគ្រាសដែលបានអង្កេតក្នុងឆ្នាំ ២០១៧-២០១៨,
- ជំរុញការចុះបញ្ជីអ្នកជាប់ពន្ធតាមរយៈទិន្នន័យចុះបញ្ជីពីក្រសួង-ស្ថាប័នពាក់ព័ន្ធ,
- ពង្រឹងការផ្ទេរសហគ្រាសពីតូចទៅមធ្យម និងមធ្យមទៅធំ និងបញ្ច្រាសមកវិញ,
- បន្តពង្រឹងការកៀរសហគ្រាសដែលបាត់ខ្លួន ក្នុងគោលដៅលុបចេញពីបញ្ជីអ្នកជាប់ពន្ធ ។



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

(២). ការផ្តល់សេវាអ្នកជាប់ពន្ធ

- ពង្រឹងការពិគ្រោះយោបល់នៅបញ្ជរផ្ទាល់ និងទទួលភ្ជាប់ពី Call Center សម្រាប់ការស្នើសុំបង់ពន្ធប្រថាប់ត្រាលើផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើចំណេញមូលធន,
- ពង្រឹងការផ្សព្វផ្សាយអប់រំដល់សាធារណជន អាជ្ញាធរដែនដី និងមន្ត្រីរាជការនៅស្ថាប័ននានា ដើម្បីបញ្ញាបវប្បធម៌បង់ពន្ធ តាមរយៈសិក្ខាសាលា ការផ្សព្វផ្សាយតាមគេហទំព័រ បណ្តាញទំនាក់ទំនងសង្គម (Facebook) នៃអគ្គនាយកដ្ឋានពន្ធដារ និងបណ្តាញព័ត៌មានផ្សេងៗ,
- រៀបចំកម្រងសំណួរ និងប្រមូលទិន្នន័យអំពីការពេញចិត្តរបស់អ្នកជាប់ពន្ធលើការផ្តល់សេវានៃការបង់ពន្ធប្រថាប់ត្រា និងពន្ធលើអចលនទ្រព្យ,
- ពន្លឿនការឆ្លើយតបចម្ងល់ និងបញ្ហារបស់អ្នកជាប់ពន្ធ,
- រៀបចំសិក្ខាសាលាស្តីពីការផ្ទេរថ្លៃចំនួនពីរដងក្នុងមួយឆ្នាំ,
- រៀបចំវេទិកាស្តីពីថ្ងៃពន្ធដាឱ្យបានយ៉ាងតិចមួយដងក្នុងមួយឆ្នាំ,
- ធ្វើការអប់រំអ្នកជាប់ពន្ធក្នុងអំឡុងពេលសវនកម្ម,
- បន្តរៀបចំវគ្គបណ្តុះបណ្តាលភ្នាក់ងារសេវាកម្មពន្ធដារ និងចេញវិញ្ញាបនបត្រភ្នាក់ងារសេវាកម្មពន្ធដារ,
- បន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាពាក់ព័ន្ធនឹងពន្ធដារ,
- រៀបចំវគ្គបណ្តុះបណ្តាលសាធារណជនអំពីជំនាញពន្ធដារ រួមទាំងការបណ្តុះបណ្តាលនៅតាមបណ្តាសាកលវិទ្យាល័យ,
- រៀបចំកម្រងសំណួរ-ចម្លើយជាប្រចាំ (FAQs) ដែលអ្នកជាប់ពន្ធងាយស្វែងរកបានតាមប្រព័ន្ធអេឡិចត្រូនិក,
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធ Call Centre ដើម្បីឆ្លើយតបទៅអ្នកជាប់ពន្ធ ប្រកបដោយវិជ្ជាជីវៈ និងទាន់ពេលវេលា,
- បន្តផ្តល់មធ្យោបាយក្នុងការពិគ្រោះយោបល់ដែលមានភាពងាយស្រួល រហ័ស ដូចជា GDT Live Chat, Email, Call Center (1277), Facebook និងពិគ្រោះយោបល់ដោយផ្ទាល់,
- បន្តរៀបចំសិក្ខាសាលាស្តីពីច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជូនអ្នកជាប់ពន្ធ ព្រមទាំងសិក្ខាសាលាផ្សព្វផ្សាយស្តីពីវិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ ក៏ដូចជាសិក្ខាសាលាស្តីពីកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា,
- ពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការដោះស្រាយរាល់ចម្ងល់ និងបញ្ហាផ្សេងៗរបស់អ្នកជាប់ពន្ធតាមរយៈលិខិត និងជួបអ្នកជាប់ពន្ធផ្ទាល់ឱ្យបានឆាប់រហ័ស,

- បន្តធ្វើការអប់រំអ្នកជាប់ពន្ធតាមរយៈវេទិកាផ្សាយផ្ទាល់ស្តីពីពន្ធដារ ដូចជា កម្មវិធីពន្ធដារកម្ពុជា - GDT Cambodia ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន,
- រៀបចំកម្មវិធី និងជួបពិភាក្សាជាមួយវិស័យឯកជន ក៏ដូចជាចូលរួមក្នុងវេទិកា/ សិក្ខាសាលា/ កម្មវិធីពាក់ព័ន្ធនឹងពន្ធដារ ដែលរៀបចំដោយវិស័យឯកជន ឬស្ថាប័នផ្សេងទៀត,
- ទទួលមតិយោបល់ត្រលប់ពីអ្នកជាប់ពន្ធតាមគ្រប់មធ្យោបាយ ដើម្បីកែលម្អរដ្ឋបាលសារពើពន្ធ,
- រៀបចំនិងធ្វើបច្ចុប្បន្នភាពខិត្តប័ណ្ណផ្សព្វផ្សាយ និងឃ្លីបអំពីប្រភេទពន្ធនីមួយៗ ដើម្បីផ្សព្វផ្សាយអំពីវប្បធម៌នៃការបង់ពន្ធ និងកាតព្វកិច្ចពន្ធដារ,
- ការផ្សព្វផ្សាយជូនដល់អ្នកជាប់ពន្ធស្តីពីការស៊ើបអង្កេតបទល្មើសពន្ធដារ តាមរយៈការរៀបចំសិក្ខាសាលា ឯកសារបោះពុម្ព និងឃ្លីបផ្សព្វផ្សាយ,
- បន្តកែលម្អគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការស្វែងរកព័ត៌មានឱ្យបានងាយស្រួលនិងឆាប់រហ័ស,
- រៀបចំផែនការ និងពង្រីកបញ្ជរពិគ្រោះយោបល់នៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ ដើម្បីទទួលសំណួរ សំណូមពរ និងឆ្លើយតបរាល់ចម្ងល់របស់អ្នកជាប់ពន្ធដោយផ្ទាល់មាត់,
- ផ្តល់សេវាឱ្យបានទាន់ពេលវេលាស្របតាមកម្រងសេវាសាធារណៈចំពោះការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដោយផ្សព្វផ្សាយជាសាធារណៈអំពីបញ្ជីរំហូរការងារ និងវីដេអូខ្លីអំពីការចុះបញ្ជី និងបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ,
- ពង្រឹង និងពន្លឿនយន្តការបង្វិលសងអាករលើតម្លៃបន្ថែម តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិ,
- ពន្លឿនការពិនិត្យឯកសារបង្វិលសង និងការផ្ទៀងផ្ទាត់វិក្កយបត្រព្រមទាំងឯកសារពាក់ព័ន្ធ ។

**(៣). ការចាត់ចែងលិខិតប្រកាស**

- ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ E-Filing និង E-payment ដើម្បីកាត់បន្ថយការជួបផ្ទាល់រវាងអ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារ,
- បន្តពង្រឹងការពិនិត្យផ្ទៀងផ្ទាត់វិក្កយបត្រអាករលើតម្លៃបន្ថែម និងប្រភេទពន្ធផ្សេងៗ,
- ពង្រីកសេវាជូនដំណឹង ឬរំលឹកអ្នកជាប់ពន្ធមកដាក់លិខិតប្រកាសពន្ធទាន់ពេលវេលា តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន,
- បន្តពង្រឹងការផ្ទៀងផ្ទាត់លើលិខិតប្រកាសចំពោះចំណូល-ចំណាយ និងគណនីយោង ដោយផ្អែកលើហានិភ័យ,
- បន្តពង្រឹងការព្យួរ ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ចំពោះសហគ្រាសដែលប្រកាសគ្មានផលរបរ ៣ ខែ ឬ ៦ ខែជាប់គ្នា,
- បន្តជំរុញការដាក់លិខិតប្រកាសឱ្យបានទាន់ពេលកំណត់ចំពោះសហគ្រាសដែលបានបង់ពន្ធ តែមិនបានដាក់លិខិតប្រកាស,



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- ពង្រឹងការដាក់លិខិតប្រកាសពន្ធតែមប្រិ៍សារពើពន្ធ តាមរយៈការធ្វើបច្ចុប្បន្នភាពបញ្ជីសហគ្រាសមិនបានដាក់លិខិតប្រកាស,
- ពង្រឹងការប្រកាសបង់ពន្ធលើអចលនទ្រព្យ ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រងពន្ធលើអចលនទ្រព្យ ។

**(៤). ការធ្វើសវនកម្ម**

- ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យប្រភពចំណូល ដោយផ្អែកលើការវិភាគ និងវាយតម្លៃផលប៉ះពាល់វដ្តធុរកិច្ច (Business Cycle),
- ពង្រឹងការត្រួតពិនិត្យលើការប្រកាសបង់ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ តាមរយៈការអញ្ជើញម្ចាស់អចលនទ្រព្យដោយផ្ទាល់ ការត្រួតពិនិត្យការប្រកាសបង់ពន្ធឡើងវិញនៅពេលអ្នកជាប់ពន្ធស្នើសុំបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះ,
- បន្តអញ្ជើញម្ចាស់អចលនទ្រព្យធំៗឱ្យមកបង់ពន្ធលើអចលនទ្រព្យឬពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- បន្តជ្រើសរើសអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់ដោយមានការដាក់ពិន្ទុតាមបែបវិទ្យាសាស្ត្រច្បាស់លាស់សម្រាប់ជាអាទិភាពក្នុងការធ្វើសវនកម្ម,
- អនុវត្តតាមប្រកាសលេខ ២៧០ សហវ. ប្រក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៩ ស្តីពីសវនកម្មពន្ធដារ,
- កាត់បន្ថយការធ្វើសវនកម្មត្រួតជាន់គ្នា ដើម្បីសម្រួលបន្ទុករបស់អ្នកជាប់ពន្ធ (សវនកម្មពេញលេញ និងមានកម្រិត),
- កែលម្អនូវវិធីសាស្ត្រកំណត់ហានិភ័យ និងធ្វើបច្ចុប្បន្នភាពរៀងរាល់ ២ ឆ្នាំម្តង,
- រៀបចំរបាយការណ៍ស្តីពីការជ្រើសរើសអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់សម្រាប់ជាអាទិភាពក្នុងការធ្វើសវនកម្ម,
- រៀបចំកិច្ចប្រជុំវាយតម្លៃប្រចាំខែ រវាងថ្នាក់ដឹកនាំទទួលបន្ទុក និងសវនករ,
- បន្តពង្រឹងការអនុវត្តការប្រើប្រាស់តែមប្រិ៍សម្រាប់បារី តាមរយៈការចុះត្រួតពិនិត្យការបិទតែមប្រិ៍លើបារីដែលផ្គត់ផ្គង់ដោយភ្នាក់ងារចែកចាយ ផ្សារទំនើប និងហាងលក់ទំនិញ,
- ទប់ស្កាត់ការចៀសវាង និងការកិបកេងបន្លំពន្ធតាមរយៈការពង្រឹងការធ្វើសវនកម្មចំពោះសហគ្រាសដែលជាបុគ្គលទាក់ទិន ឬសហគ្រាសសម្ព័ន្ធញាតិ,
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ តាមរយៈការជ្រើសរើសអង្គភាពរងសវនកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពនិងគុណភាពការងារ របស់អង្គភាពចំណុះអគ្គនាយកដ្ឋានពន្ធដារ,
- ពង្រឹងប្រសិទ្ធភាព និងគុណភាពការងារតាមរយៈការអនុវត្តអនុសាសន៍ជាលទ្ធផលនៃសវនកម្មផ្ទៃក្នុងដែលស្របតាមមុខងារ វិធាន និងនីតិវិធីជាធរមាន និងរាយការណ៍ពីផែនការសកម្មភាពសម្រាប់កែលម្អ ។

(៥). **ការស៊ើបអង្កេត**÷ពង្រឹងមុខងារស៊ើបអង្កេតបទល្មើសពន្ធដារឱ្យមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ និងបង្ក្រាបការគេចវេះពន្ធ និងការប្រព្រឹត្តបទល្មើសពន្ធដារ តាមរយៈ÷

- ការបន្តរៀបចំ កែលម្អ និងធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសពន្ធដារ,
- ការពង្រឹងការប្រមូលព័ត៌មាន និងទទួលព័ត៌មានសម្ងាត់ឱ្យទាន់ពេលវេលា ដើម្បីកំណត់ និងជ្រើសរើសអ្នកជាប់ពន្ធដែលប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ,
- ការបន្តរៀបចំ កែលម្អ និងធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំស្តីពីវិធីសាស្ត្រក្នុងការកំណត់ហានិភ័យអ្នកជាប់ពន្ធដើម្បីកំណត់អត្តសញ្ញាណអ្នកជាប់ពន្ធដែលមានហានិភ័យខ្ពស់ ដើម្បីឱ្យមានភាពពេញលេញ និងឆ្លើយតបនឹងការវិវឌ្ឍបរិបទធុរកិច្ច,
- ការបង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មលើការកំណត់អត្តសញ្ញាណអ្នកប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយផ្អែកលើសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសពន្ធដារ,
- ការពង្រឹងការអនុវត្តនីតិវិធីស៊ើបអង្កេតបទល្មើសពន្ធដារ រួមមាន÷
    - ការស្វែងរកអ្នកជាប់ពន្ធ និង/ឬឃាត់ខ្លួនអ្នកជាប់ពន្ធមកសាកសួរ,
    - ការដាក់បណ្តឹងទៅព្រះរាជអាជ្ញានិងតុលាការ,
    - ការឆែកឆេរ និងរឹបអូសឯកសារនិងភ័ស្តុតាង,
    - ការឃុំគ្រងទ្រព្យសម្បត្តិ និងឃាត់ខ្លួនជនសង្ស័យ ។
- ការជ្រើសរើសអ្នកជាប់ពន្ធដែលគេចវេះពន្ធធ្ងន់ធ្ងរដើម្បីធ្វើការស៊ើបអង្កេត,
- ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មានកំណត់បទល្មើពន្ធដារ ស៊ើបអង្កេតបទល្មើសពន្ធដារ និងប្តឹងចោទប្រកាន់បទល្មើសទៅព្រះរាជអាជ្ញា និងតុលាការ និងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើការងារស៊ើបអង្កេតបទល្មើសពន្ធដារ ។

(៦). **ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា**

- បន្តជំរុញការប្រមូលបំណុលពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់,
- ដោះស្រាយរាល់ការតវ៉ានានាពាក់ព័ន្ធនឹងពន្ធលើវិស័យអចលនទ្រព្យ,
- អនុវត្តវិធានការទារ និងតឹងទារបំណុលពន្ធចំពោះសហគ្រាសដែលមានហានិភ័យខ្ពស់,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងបំណុល (Tax Arrears System),
- ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលជំពាក់បំណុលពន្ធ តាមរយៈការចុះអង្កេតដល់ទីតាំងសហគ្រាសក្នុងគោលដៅគ្រប់គ្រងបំណុលពន្ធឱ្យមានប្រសិទ្ធភាព,
- កំណត់បំណុលពន្ធជាអាទិភាពដែលអាចប្រមូលបានតាមរយៈការធ្វើចំណាត់ថ្នាក់បំណុលពន្ធ,
- បន្តពង្រឹងការអនុវត្តការប្រមូលបំណុលពន្ធ និងវិធានការតឹងទារបំណុលពន្ធ,



ឯកសារមន្ត្រីរាជការ: | https://t.me/oa_channel

- បង្កើតមធ្យោបាយបន្ថែមក្នុងការផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងការអញ្ជើញមកទូទាត់បំណុលពន្ធឱ្យបានលឿនដល់សហគ្រាសតាមរយៈសារអេឡិចត្រូនិក,
- បង្កើតយន្តការផ្ដល់ព័ត៌មាន និងរំលឹកអ្នកជាប់ពន្ធអំពីបំណុលពន្ធចលនទ្រព្យនិងអចលនទ្រព្យ,
- បន្តពង្រឹងលទ្ធផលដោះស្រាយបណ្ដឹងតវ៉ាពន្ធដារ តាមរយៈការដាក់ចេញនូវកម្មវិធីប្រជុំវាយតម្លៃប្រចាំខែ រវាងថ្នាក់ដឹកនាំទទួលបន្ទុក និងមន្ត្រី ដើម្បីដោះស្រាយបញ្ហាប្រឈម ។

**(៧). បច្ចេកវិទ្យាព័ត៌មាន**

- ធ្វើទំនើបកម្មនូវប្រព័ន្ធ E-Filing និង E-Payment ដើម្បីផ្ដល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធ,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធ E-Filling,
- រៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្មលើការកំណត់ហានិភ័យអ្នកជាប់ពន្ធត្រូវបានបង្កើត និងធ្វើតេស្តសាកល្បង,
- កសាង និងអនុវត្តប្រព័ន្ធត្រួតពិនិត្យដំណើរការប្រតិបត្តិការស្ទួលទាន់ពេលវេលា ដើម្បីពង្រឹងប្រសិទ្ធភាពតាមដានវឌ្ឍនភាពសូចនាករសមិទ្ធកម្មគន្លឹះ,
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,
- សិក្សា និងពិនិត្យលទ្ធភាព ដើម្បីឈានបង្កើតឱ្យមានមជ្ឈមណ្ឌលរក្សាទិន្នន័យរួម (Big Data),
- ចូលរួមជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៃច្រកចេញចូលនៃប្រព័ន្ធអ៊ិនធឺណិតជាតិ (National Internet Gateway) និងប្រព័ន្ធទូទាត់ (Payment Gateway),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស (Biz Registration System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី លើប្រព័ន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្តតាម Online (Online Vehicle Transferring Management System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធចុះបញ្ជីតាម Online (Online Registration System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីលើប្រព័ន្ធ Help Desk System ដើម្បីផ្ដល់ការគាំទ្របច្ចេកទេសដល់អ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធភាព, ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីលើកម្មវិធីពិនិត្យ និងតាមដានឯកសារ (GDT Check & Track App),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងសវនកម្ម (Tax Audit System),

- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីអចលនទ្រព្យ (Property Tax System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធគ្រប់គ្រងសន្លឹកតែមប្រិ៍ (Stamp Management System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធបង់ប្រាក់ពន្ធតាម Online (E-Payment System) និងអាចដំណើរការលើ Smart Devices បាន,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងការបង់ពន្ធ (Tax Payment Single Invoice System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងតាមដានឯកសារ (Document Tracking System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ចំណូលពន្ធដារដើម្បីងាយស្រួលក្នុងការពិនិត្យ តាមដាន និងវិភាគលើចំណូល (Tax Revenue Reporting System),
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HR System),
- អនុវត្តផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសារពើពន្ធ ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញនិងប្រទាក់ក្រឡា, ប្រព័ន្ធវិភាគទិន្នន័យ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអ្នកជាប់ពន្ធពេញលេញ, ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធ និងប្រព័ន្ធចែករំលែកទិន្នន័យអន្តរស្ថាប័ន ដោយរួមបញ្ចូលទាំងផែនការវិនិយោគ,
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពការងារ,
- មន្ត្រីពាក់ព័ន្ធអាចរកឯកសារសម្រាប់គោលបំណងសវនកម្ម និងស៊ើបអង្កេត តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យ,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធផ្លាស់ប្តូរទិន្នន័យ (សន្ទានកម្ម) របស់អគ្គនាយកដ្ឋានពន្ធដារ ជាមួយប្រព័ន្ធផ្លាស់ប្តូរទិន្នន័យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា,
- ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធផ្លាស់ប្តូរទិន្នន័យ (សន្ទានកម្ម) របស់អគ្គនាយកដ្ឋានពន្ធដារជាមួយប្រព័ន្ធផ្លាស់ប្តូរទិន្នន័យរបស់ FMIS និងក្រសួងសាធារណការនិងដឹកជញ្ជូន,
- ជំរុញ និងពង្រឹងការផ្តល់ឯកសារពាក់ព័ន្ធនឹងអ្នកជាប់ពន្ធឱ្យបានត្រឹមត្រូវ និងទៀងទាត់តាមគោលការណ៍ណែនាំ ដើម្បីរក្សាទុកក្នុងមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ និងឃ្លាំងឯកសារ ។

ឯកសារផ្សព្វផ្សាយសាធារណៈ | https://t.me/oa_channel

២.៣.៣-ផ្នែកចំណូលមិនមែនសារពើពន្ធ÷ ដើម្បីសម្រេចបានតាមផែនការចំណូលដែលបានកំណត់ វិធានការមួយចំនួននឹងត្រូវដាក់ចេញ ដូចខាងក្រោម÷

- ពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នប្រមូលចំណូល ដើម្បីបន្តអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ អនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីពង្រឹងការគ្រប់គ្រងស្ថាប័ន ការទទួលខុសត្រូវច្បាស់លាស់ ការដាក់ទណ្ឌកម្ម សវនកម្ម និងអធិការកិច្ច ជាដើម,
- ពង្រីកវិសាលភាពការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដល់រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់,
- ពង្រីកវិសាលភាពការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) នៅរដ្ឋបាលថ្នាក់ជាតិសម្រាប់ជំហានទី ៣,
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់,
- ជំរុញអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមអនឡាញដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ,
- បន្តស្វែងរកមុខចំណូលថ្មីៗ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលដែលមានស្រាប់ ពិសេសមុខចំណូលដែលមិនប៉ះពាល់ដល់កម្រិតជីវភាពរបស់ប្រជាជនទូទៅ,
- ពង្រឹងយន្តការគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល,
- បន្តពង្រឹងការគ្រប់គ្រង និងអនុវត្តនូវកិច្ចសន្យាជួលអគារ អចលនទ្រព្យ ជួលកោះ និងឆ្នេរ ដោយផ្អែកលើគោលការណ៍ទីផ្សារ ព្រមទាំងតាមដានយ៉ាងម៉ឹងម៉ាត់ការអនុវត្តកាតព្វកិច្ចរបស់ក្រុមហ៊ុនការបង់ចំណូលចូលរដ្ឋ និងការអនុវត្តយន្តការទឹងទារបំណុល ពិន័យ លុបចោលកិច្ចសន្យា ឬដកហូតដកប្រាក់កក់ ក្នុងករណីក្រុមហ៊ុនមិនបំពេញតាម,
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

## ២.៤-ការអនុវត្តចំណាយថវិកា

រាជរដ្ឋាភិបាលត្រូវចំណាយថវិការដ្ឋសរុបចំនួន ៣៤ ៧០៨,៦ ប៊ីលានរៀល ត្រូវជា ២៧,៩៥% នៃ ផ.ស.ស. មានកំណើន ៨,៤% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ។ **ចំណាយចរន្តថវិកាថ្នាក់ជាតិ** មានចំនួន ១៩ ១១១,៧ ប៊ីលានរៀល ត្រូវជា ១៥,៣៩% នៃ ផ.ស.ស. គឺកើនឡើង ៩,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។ **ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោង ១៣ ៤៦៥,២ ប៊ីលានរៀល, មានសមាមាត្រស្មើនឹង ៤១,៣% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ១០,៨៤% នៃ ផ.ស.ស., កើនឡើង ៣,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ។

ទន្ទឹមនេះ ដើម្បីធានាបានថា ថវិកាឆ្នាំ ២០២២ ពិតជាដើរតួនាទីជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពពិតប្រាកដសម្រាប់អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល, ការគ្រប់គ្រងនូវការអនុវត្តថវិកាត្រូវតែហ្មត់ចត់ និងម៉ឺងម៉ាត់ ទាំងក្នុងការគ្រប់គ្រង, ការប្រមូលចំណូល និងក្នុងការអនុវត្តចំណាយ ដោយត្រូវពង្រឹងការគោរពច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិថ្នាក់ក្រោមជាតិ, ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុដទៃទៀត ជាពិសេសការអនុវត្តចំណាយត្រូវមានប្រសិទ្ធភាព ចំទិសដៅអាទិភាពពិតប្រាកដ មានភាពសន្សំសំចៃខ្ពស់ និងស្ថិតក្នុងរង្វង់នៃលទ្ធភាពឥណទានថវិកាដែលមាន ។ ទន្ទឹមគ្នានេះដែរ ត្រូវជំរុញអនុវត្តឱ្យបានជោគជ័យនូវបណ្តាផែនការសកម្មភាព និងវិធានការកែលម្អការគ្រប់គ្រងថវិកា និងបន្តដាក់ចេញនូវផែនការសកម្មភាព និងវិធានការថ្មីៗទៀត ដើម្បីជម្នះ និងទប់ទល់ផលប៉ះពាល់អវិជ្ជមាននានាបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងបញ្ហាប្រឈមផ្សេងៗទៀតដែលអាចកើតមានជាយថាហេតុ ។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមគូសរំលេចនូវបណ្តានីតិវិធីហិរញ្ញវត្ថុសាធារណៈ និងវិធានការអនុវត្តដូចខាងក្រោម÷

**២.៤.១-ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម**

ការស្នើសុំ និងការផ្តល់ធានាចំណាយ ត្រូវអនុវត្តតាមប្រភេទចំណាយធំៗបី ដូចខាងក្រោម÷

- **ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)÷** ចំណាយដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខ័ណ្ឌ និងកំប្រាក់ពីក្រសួងមុខងារសាធារណៈដែលមានគោលរបប និងគោលការណ៍កំណត់ ពុំតម្រូវឱ្យមានការសុំធានាចំណាយដាច់ដោយឡែកឡើយ ដោយអនុញ្ញាតឱ្យបោះផ្សាយអាណត្តិបើកប្រាក់ ដោយឈរលើមូលដ្ឋានឥណទានថវិកាដែលមានតែម្តង ។ ក្នុងន័យនេះ ជាយថាហេតុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចនឹងចាត់វិធានការបង្កកឥណទានថវិកាចំណាយជំពូកផ្សេងទៀត ក្នុងករណីពិនិត្យឃើញថា ឥណទានថវិកាបន្ទុកបុគ្គលិករបស់ក្រសួង-ស្ថាប័នមានមិនគ្រប់ចំនួន ស្របតាមការគណនាដោយផ្អែកលើទិដ្ឋាការបញ្ជាក់ពីភាពត្រឹមត្រូវនៃចំនួនក្របខ័ណ្ឌ និងកំប្រាក់ពីក្រសួងមុខងារសាធារណៈ ។ ដូច្នេះ ក្នុងពេលអនុវត្ត ក្រសួង-ស្ថាប័ន ត្រូវយកចិត្តទុកដាក់ប្រកប-ដោយការទទួលខុសត្រូវខ្ពស់ក្នុងការគ្រប់គ្រងឥណទានថវិកាបន្ទុកបុគ្គលិកនេះ ឱ្យបានគ្រប់គ្រាន់ ដើម្បីចៀសវាងការរាំងស្ទះដល់ការបើកផ្តល់ប្រាក់បៀវត្ស ។ ឥណទានថវិកាជំពូក ៦៤ នឹងមិនត្រូវបានអនុញ្ញាតឱ្យបន្ថែមជូននោះទេ វៀរលែងតែក្នុងករណីមានតម្រូវការបន្ថែមដោយសាររាជរដ្ឋាភិបាលមានការកែប្រែគោលនយោបាយឬផ្តល់គោលការណ៍ដោយឡែក ដែលអនុញ្ញាតឱ្យក្រសួង-ស្ថាប័នជ្រើសរើសក្របខ័ណ្ឌថ្មី ជាពិសេសក្នុងអំឡុងឆ្នាំអនុវត្ត ។ ទន្ទឹមនេះ អនុវត្តតាមការសម្រេចរបស់រាជរដ្ឋាភិបាល លើវិធានការគ្រប់គ្រងបន្ទុកបុគ្គលិកនេះ, គ្រប់ក្រសួង-ស្ថាប័នត្រូវគោរពឱ្យបានម៉ឺងម៉ាត់តាមគោលការណ៍÷ (១)-ការដំឡើងឋានន្តរស័ក្តិនិងថ្នាក់ជូនមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីរាជការស៊ីវិលផ្សេងៗទៀត មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទសម្រាប់ឆ្នាំ ២០២១ និងឆ្នាំ ២០២២ ត្រូវអនុវត្តជាធម្មតាអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និង (២)-ការបម្រែបម្រួលស្ថានភាពថវិកានៅក្នុងតារាងទូទាត់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល នៃក្រុមនីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីរាជការស៊ីវិល

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ផ្សេងទៀត មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទ ដែលត្រូវបានដំឡើងឋានន្តរស័ក្តិ និងថ្នាក់នៅឆ្នាំ ២០២១ និងឆ្នាំ ២០២២ ត្រូវបានអនុវត្តចាប់ពីខែ ឧសភា ឆ្នាំ ២០២២ ដោយមិនមានការអនុវត្តប្រតិសកម្មឡើយ ។

ជាមួយគ្នានេះ, គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវ÷

- ពង្រឹងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់នូវចំនួនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ក្នុងគោលបំណងផ្គូផ្គងធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីក្របខ័ណ្ឌចូលថ្មី ក្នុងករណីមានការសម្រេចដោយឡែកពីប្រមុខរាជរដ្ឋាភិបាល ។ ទន្ទឹមនេះ មន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលត្រូវចូលបម្រើការងារវិញ ត្រូវតែជាកម្មវត្ថុនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ ។

- ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការប្រើប្រាស់ប្រាក់រង្វាន់ពីកម្រៃសេវាសាធារណៈ ទាំងសម្រាប់ការលើកទឹកចិត្តដល់មន្ត្រីរាជការ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងទាំងសម្រាប់គាំទ្រដល់ការពង្រឹងយន្តការប្រមូលចំណូល ។

• **ចំណាយក្រៅបន្ទុកបុគ្គលិក÷** រួមមាន ចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ចំណាយលើអគ្គិសនី ទឹក ទូរស័ព្ទ ទូរគមនាគមន៍ និងចំណាយផ្សេងៗទៀតដែលមានគោលការណ៍ និងគោលរបបកំណត់រួចហើយ ពុំតម្រូវឱ្យមានការស្នើសុំធានាចំណាយឡើយ ។

ពាក់ព័ន្ធនឹងមុខសញ្ញាចំណាយតាមរជ្ជទេយ្យបុរេប្រទាន ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវរៀបចំបង្កើតតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ដោយត្រូវកម្រិតកំណត់ទឹកប្រាក់តាមមុខសញ្ញាចំណាយឱ្យសមស្របតាមចរិតចំណាយតាមរជ្ជទេយ្យបុរេប្រទាន ដូចមានលម្អិតក្នុងឧបសម្ព័ន្ធទី ១ នៃប្រកាស ៦៦៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ដោយចៀសវាងយកចំណាយដែលជាកម្មវត្ថុសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឬអនុវត្តតាមនីតិវិធីទូទាត់ត្រង់ មកគ្រោងចូលក្នុងរជ្ជទេយ្យបុរេប្រទាន ហើយពុះច្រៀកការទិញ ឬចំណាយ ឬបំបែកគម្រោងជាគម្រោងតូចៗ ។ ដោយឡែក ចំពោះអាជ្ញាធរ ឬអង្គភាពថវិកាដែលមានមាតិកាចំណាយតែមួយខ្ទង់ក្នុងជំពូក ៦៥ "ឧបត្ថម្ភធន" ត្រូវរៀបចំតារាងលម្អិតផ្ទៃក្នុងតាមមុខសញ្ញាចំណាយតាមមាតិកាថវិកានៃចំណាត់ថ្នាក់សេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានច្បាស់លាស់ក្នុងការបង្កើតរជ្ជទេយ្យបុរេប្រទាន ស្របតាមឧបសម្ព័ន្ធទី ១ នៃប្រកាស ៦៦៣ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ដោយមិនមែនផ្អែកតាមមូលដ្ឋាន ៣០% ធៀបនឹងឥណទានថវិកាសរុបនៃអនុគណនីដែលមានមួយខ្ទង់នៃជំពូក ៦៥ "ឧបត្ថម្ភធន" នោះទេ ។

ចំពោះចំណាយប្រាក់បេសកកម្មក្នុងប្រទេស, ចំណាយសម្រាប់ការបណ្តុះបណ្តាល កិច្ចប្រជុំផ្សេងៗ សិក្ខាសាលា ត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងតាមនីតិវិធីទូទាត់ត្រង់ ដោយត្រូវអនុលោមតាមអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេសនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ

និងប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។ ចំពោះចំណាយប្រភេទនេះ អាណាប័កត្រូវគ្រោងចំណាយសម្រាប់អនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន តាមរយៈរជ្ជទេយ្យករបុរេប្រទាន និងតាមនីតិវិធីទូទាត់ត្រង់ ទៅតាមស្ថានភាពអនុវត្តជាក់ស្តែង ។ រជ្ជទេយ្យករបុរេប្រទាន/រជ្ជទេយ្យករបុរេប្រទានរង ត្រូវទុកដាក់ថែរក្សានូវសាច់ប្រាក់ដែលបានទទួលពីគណនេយ្យករសាធារណៈ ព្រមទាំង ទុកដាក់ថែរក្សាលិខិតយុត្តិការកាន់កាប់បញ្ជីបេឡាដោយឡែកសម្រាប់តាមដានចំណូល-ចំណាយ និងប្រាក់ដែលនៅសល់ ។ ទន្ទឹមនេះ ការទូទាត់ត្រូវបានអនុញ្ញាតឱ្យធ្វើទៅតាមទំហំទឹកប្រាក់ចំណាយជាក់ស្តែង ដោយមិនមានកំណត់ទឹកប្រាក់អតិបរមាក្នុងមួយសក្ខីប័ត្រចំណាយឡើយ ។ អាណាប័កត្រូវប្រមូល និងរៀបចំអាណត្តិបើកប្រាក់/អាណត្តិនិយ័តកម្ម និងលិខិតយុត្តិការចំណាយដើម្បីស្នើសុំទូទាត់តែម្តង ។ ទោះជាយ៉ាងនេះក្តី ក៏មិនមានន័យថា អាណាប័កនឹងទទួលបានការទូទាត់ ឬការបើកផ្តល់តាមសំណើជាស្វ័យប្រវត្តិនោះទេ ។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវផ្តោតការយកចិត្តទុកដាក់ ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការរៀបចំសំណើឱ្យទាន់ពេលវេលា ដោយភ្ជាប់មកជាមួយនូវឯកសារ និងលិខិតយុត្តិការត្រឹមត្រូវ និងគ្រប់គ្រាន់ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។ ចំពោះអត្រាគោលរបប និងនីតិវិធីចំណាយនេះ ត្រូវបន្តអនុវត្តរហូតដល់មានបទដ្ឋានគតិយុត្តថ្មីមកជំនួស ។

ចំពោះមុខសញ្ញាចំណាយមួយចំនួន ដែលជាចំណាយជំនួយសង្គមរបស់រាជរដ្ឋាភិបាល ដែលមានលក្ខណៈចាំបាច់ និងបន្ទាន់ ក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានអនុញ្ញាតឱ្យអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន តាមលំនាំរជ្ជទេយ្យបុរេប្រទាន ដោយអនុលោមតាមយន្តការជុំបង្វិល និងការបំពេញបេឡាឡើងវិញ ។

ជារួម នីតិវិធីអនុវត្តចំណាយថវិកាត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្តដែលត្រូវបានដាក់ចេញ រួមមាន÷

- អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលតម្រូវឱ្យគ្រប់ភ្នាក់ងារប្រតិបត្តិគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមមាតិកាគណនីនៃប្លង់គណនេយ្យថវិកាថ្មី និងប្រភេទចំណាយក្នុងគម្រោង/កម្មវិធីហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍
- អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេសនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៧៧០ សហវ.ប្រក ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីចំណាយថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ប្រព័ន្ធធារាសាស្ត្រ
- ប្រកាសលេខ ៦៦៣ សហវ. ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីនីតិវិធីចំណាយតាមវជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៥៣៣ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីចំណាយថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវថ្នល់ ផ្លូវជនបទ ស្ពាន និងលូ
- ប្រកាសលេខ ១០៨៤ សហវ.អថ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ២០៧ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៩ ស្តីពីនីតិវិធី និងបែបបទនៃការអនុវត្តចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់)
- ប្រកាសលេខ ១០២២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៨៨២ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់គម្រោងនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៧៣២ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៥៤៩ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួល និងបំពេញបន្ថែមលេខកូដចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ៥០៣ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ទិញចំណីសត្វ និងចំណីត្រីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសលេខ ៥៥៤ សហវ.ប្រក ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា

- ប្រកាសអន្តរក្រសួងលេខ ៣០២ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៃក្រសួងសុខាភិបាល
- ប្រកាសអន្តរក្រសួងលេខ ៧២២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីគោលរបប និងនីតិវិធីចំណាយថវិកាសម្រាប់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ប្រកាសលេខ ១០២ សហវ. ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសអន្តរក្រសួងលេខ ៣៦៦ សហវ. ប្រក ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការអនុវត្តថវិកាសម្រាប់ដំណើរការសាលារៀនសាធារណៈ
- ប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យ រជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាវិនិយោគសាធារណៈ និងជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានអនុវត្តដោយអង្គភាពរដ្ឋ
- សារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីរាជការ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត ។

• **ចំណាយផ្សេងទៀត** ដែលត្រូវបានចាត់ទុកថាមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម ហើយដែលមិនស្ថិតក្នុងប្រភេទចំណាយដែលត្រូវបានគូសរំលេចខាងលើ ក្រសួង-ស្ថាប័នត្រូវស្នើសុំធានាចំណាយជាមុន ដោយត្រូវមានការពន្យល់ច្បាស់លាស់អំពីភាពចាំបាច់, អំពីគោលការណ៍អនុញ្ញាត ឬ/និង អំពីឯកសារគាំទ្រផ្សេងៗ ។

**២.៤.២-ចំណាយដែលតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ**

មុខចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តម្រូវឱ្យមានការសុំធានាចំណាយ ដោយក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ និងត្រូវគោរពឱ្យបាននូវគោលការណ៍សំខាន់ជាសារវន្ត ដូចខាងក្រោម÷

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- មុខចំណាយត្រូវស្របតាមផែនការលទ្ធកម្ម ។ ចំពោះចំណាយនេះ បើមិនមានបញ្ចូលក្នុងផែនការលទ្ធកម្មទេ មិនត្រូវបានអនុញ្ញាតឱ្យស្នើសុំ ឬផ្ដល់ធានាចំណាយឡើយ លើកលែងតែករណីដែលមានចែងនៅក្នុងសារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន ដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា ។

- ការរៀបចំមុខចំណាយសម្រាប់ផែនការលទ្ធកម្ម ត្រូវស្របតាមស្មារតីនៃការចរចាថវិកា ។

- ក្នុងករណីក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលមិនបានផ្ញើផែនការលទ្ធកម្មមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទាន់ពេលវេលាកំណត់នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) ត្រូវផ្អែកលើស្មារតីនៃការចរចាថវិកា និងកំណត់ហេតុប្រជុំ អនុម័តផែនការលទ្ធកម្មជូនតែម្ដង ។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងចាត់វិធានការនានា រួមទាំងការដកសិទ្ធិសម្រេចនូវកម្រិតទឹកប្រាក់ក្នុងកិច្ចលទ្ធកម្មសាធារណៈមួយផ្នែក ឬទាំងស្រុងមកវិញ ចំពោះក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលណាដែលខកខាន ឬយឺតយ៉ាវក្នុងការផ្ញើផែនការលទ្ធកម្ម ។**

- ទន្ទឹមនេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានរៀបចំកែសម្រួលផែនការលទ្ធកម្មបានត្រឹមត្រូវ និងផ្ញើមកទាន់ពេលវេលា ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) តែមិនទទួលបាននូវការអនុម័តទាន់ពេលវេលាមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា ផែនការលទ្ធកម្មនោះត្រូវបានចាត់ទុកថាទទួលបានការអនុម័តដោយស្វ័យប្រវត្តិពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- ការផ្ដល់ធានាចំណាយ និងការផ្ដល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវតែមានការស្នើសុំជាលាយលក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិជាដាច់ខាត ។

- ការស្នើសុំ និងផ្ដល់ធានាចំណាយ ទាំងចំណាយចរន្ត និងចំណាយមូលធន/ចំណាយវិនិយោគ ត្រូវអនុវត្តក្នុងរង្វង់ឥណទានថវិកាដែលបានអនុម័តដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងក្នុងក្របខ័ណ្ឌនៃការធ្វើវិចារណកម្មចំណាយជាយថាហេតុរបស់រាជរដ្ឋាភិបាល ។

- ការអនុវត្តចំណាយសម្រាប់ការជួសជុល ក្នុងក្របខ័ណ្ឌចំណាយចរន្ត ក្រសួង-ស្ថាប័នត្រូវរួសរាន់លើកសំណើសុំធានាចំណាយនៅក្នុងត្រីមាសទី ១ ឬយ៉ាងយូរត្រឹមត្រីមាសទី ២ ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងធានាឱ្យការទូទាត់អាចអនុវត្តបានទាន់ពេលវេលា លើកលែងតែចំណាយជួសជុលហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលជាកម្មវត្ថុនៃការយោងបន្តទៅការិយបរិច្ឆេទឆ្នាំបន្ទាប់ ។ ទោះជាយ៉ាងនេះក្ដី ក្រសួង-ស្ថាប័នក៏ចាំបាច់ត្រូវត្រៀមថវិកាទុកសម្រាប់អនុវត្តការងារជួសជុលតូចតាច ដែលអាចកើតមានជាយថាហេតុ ជាពិសេសការងារដែលមានទឹកប្រាក់ក្រោម ៤០ លានរៀល ឬមុខចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្ម តាមនីតិវិធីស្ទង់តម្លៃដែលអាចសុំធានាចំណាយនៅក្នុងត្រីមាសទី ៣ នៃឆ្នាំបាន ។ ដោយឡែកចំពោះចំណាយសម្រាប់ការជួលសេវាកម្មលើការសិក្សាស្រាវជ្រាវ ឬពិសោធន៍ ក្រសួង-ស្ថាប័ន ក៏ត្រូវរួសរាន់

លើកសំណើសុំធានាចំណាយនៅក្នុងត្រីមាសទី ១ ឬយ៉ាងយូរត្រឹមត្រីមាសទី ២ នៃឆ្នាំថវិកាផងដែរ ដើម្បីធានាភាពទាន់ពេលវេលានៃការបើកផ្តល់សាច់ប្រាក់ និងការទូទាត់បិទបញ្ជីចំណាយ ។

- ដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រង និងអនុវត្តចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ (គម្រោងវិនិយោគផ្ទាល់) ក្រសួងដែលអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាពិសេស ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយមត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការពន្លឿនការស្នើសុំគោលការណ៍ធានាចំណាយឱ្យបានចាប់ពីដើមខែមករា នៃឆ្នាំអនុវត្តថវិកា ព្រមទាំងត្រូវជំរុញឱ្យដំណើរការនៃការស្ថាបនា ស្តារ និងជួសជុលផ្លូវ-ថ្នល់ និងប្រព័ន្ធធារាសាស្ត្រប្រព្រឹត្តទៅនៅក្នុងអំឡុងរដូវរាំងភ្លៀង ដែលជាពេលវេលាអំណោយផលសម្រាប់ផ្នែកបច្ចេកទេសនៃការងារសាងសង់ព្រមទាំងត្រូវគិតគូររៀបចំកិច្ចដំណើរការសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឱ្យបានទាន់ពេលវេលាផងដែរ ។ ជាមួយគ្នានេះ ក្រសួងអាណាប័កក៏ត្រូវសិក្សាគម្រោង ដោយធានាឱ្យមានការឆ្លើយតបទៅភាពធន់នឹងការប្រែប្រួលអាកាសធាតុ ។ ដោយឡែក ក្រសួង-ស្ថាប័នផ្សេងៗទៀត (ក្រៅពីក្រសួងទាំងបីខាងលើ) ដែលទទួលបានថវិកាចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ (គម្រោងវិនិយោគផ្ទាល់) ក៏ត្រូវពន្លឿនការស្នើសុំគោលការណ៍ធានាចំណាយ និងជំរុញការអនុវត្តកិច្ចលទ្ធកម្មឱ្យបានទាន់ពេលវេលា ដើម្បីឆាប់ទទួលបានកិច្ចសន្យាអនុវត្តគម្រោងក្នុងគោលដៅបង្កើនប្រសិទ្ធភាពអនុវត្តគម្រោងឱ្យបានទាន់រដូវកាល និងទទួលបានការទូទាត់ទាន់ពេលវេលាតាមលក្ខខណ្ឌនៃកិច្ចសន្យា ។ លើសពីនេះទៀត, ក្រសួង-ស្ថាប័នដែលទទួលបានថវិកាបុរេប្រទាន (គម្រោងវិនិយោគផ្ទាល់) សម្រាប់ការចាប់ផ្តើមអនុវត្តការងារត្រូវរួសរាន់រៀបចំស្នើសុំទូទាត់ជម្រះថវិកាបុរេប្រទានឱ្យបានទាន់ពេលវេលា ដើម្បីជៀសវាងការកកស្ទះថវិកាបុរេប្រទានមិនបានទូទាត់យូរឆ្នាំ ដែលជាបច្ច័យនាំឱ្យក្លាយទៅជាបុរេប្រទានរ៉ាំរ៉ៃ ។

- មុខចំណាយដែលស្នើសុំ ត្រូវមានឥណទានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្ត ។ ចំពោះការចេញធានាចំណាយដោយគ្មានឥណទានថវិកា គឺមិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ ក្នុងន័យនេះ ការស្នើសុំធានាចំណាយត្រូវគិតដល់÷

- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទាន និងចំណាយថវិកាបុរេ-ប្រទាន ដោយរាប់ទាំងចំណាយថវិកាបុរេប្រទានមុនឆ្នាំ ២០២២ ប្រសិនបើមាន
- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយដែលបានធានាចំណាយរួច
- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយដែលចាំបាច់ខានមិនបាន ដែលអាចកើតមាននាពេលខាងមុខ ។

- ដើម្បីបង្កើនប្រសិទ្ធភាពចំណាយ និងធានាបាននូវភាពទាន់ពេលវេលានៃការអនុវត្តថវិកាកម្មវិធីក្រសួង-ស្ថាប័ន ក៏ដូចជាអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវបានអនុញ្ញាតឱ្យរៀបចំលើកសំណើសុំថវិកាចំណាយជាកញ្ចប់ប្រចាំឆមាស មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្តល់ទិដ្ឋាការធានាចំណាយ ដោយផ្អែកលើ



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ភាពច្បាស់លាស់ និងត្រឹមត្រូវនៃសកម្មភាពរបស់កម្មវិធី និងភាពត្រឹមត្រូវនៃផែនការលទ្ធកម្ម ។ លើកលែងតែសកម្មភាពថ្មីមិនមាននៅក្នុងផែនការសកម្មភាពនៃថវិកាកម្មវិធី និងចំណាយដែលមានវេទយិតភាពខ្ពស់ ដែលត្រូវជាកម្មវត្ថុនៃការពិភាក្សា និងផ្តល់ធានាចំណាយដោយឡែកជាករណីពិសេស។ **រាល់សកម្មភាព ដែលបានផ្តល់ធានាចំណាយរួចហើយ ប្រសិនបើក្រសួង-ស្ថាប័នមិនព្រមអនុវត្ត នឹងត្រូវជាកម្មវត្ថុនៃការលុបធានាចំណាយចោលវិញ នៅឆមាសបន្ទាប់ ។**

- ចំពោះមុខចំណាយធំៗ និងសំខាន់ៗ សម្រាប់បម្រើឱ្យសេចក្តីត្រូវការក្នុងការផ្តល់សេវាសាធារណៈ និងកិច្ចដំណើរការរបស់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទនីមួយៗ បែរជាមានការយឺតយ៉ាវ ឬមិនមានការរួសរាន់ស្នើសុំធានាចំណាយឱ្យបានទាន់មុនខែ មិថុនា ឆ្នាំ ២០២២, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបង្កក ឬកាត់ចេញតែម្តងនូវមុខចំណាយទាំងនោះ, ទោះបីមានក្នុងផែនការលទ្ធកម្មហើយក៏ដោយ, លើកលែងតែមុខចំណាយនោះមានភាពចាំបាច់ និងមានការពន្យល់ឱ្យបានច្បាស់លាស់អំពីមូលហេតុ ។

- គម្រោងចំណាយត្រូវមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយត្រូវមានបទដ្ឋានបច្ចេកទេស ឬយថាប្រភេទច្បាស់លាស់ដែលអាចជាមូលដ្ឋានសម្រាប់ការពិនិត្យអំពីភាពសមស្របនៃថ្លៃ, និងអំពីភាពចាំបាច់នៃគម្រោង ឬការងារ ។ ក្នុងការលើកសំណើសុំធានាចំណាយ ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ចាំបាច់ត្រូវគិតគូរឱ្យបានស្រេចបាច់អំពីតម្លៃស្របតាមទីផ្សារអំពីបរិមាណ និងគុណភាពនៃទំនិញ និងសំណង់ ដែលត្រូវធ្វើកិច្ចលទ្ធកម្មសាធារណៈ មុននឹងសុំធានាចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្តល់ធានាចំណាយដោយផ្អែកលើភាពសមស្របនៃថ្លៃទីផ្សារធ្វើជាមូលដ្ឋាន ។

- គម្រោងចំណាយត្រូវមានភាពចាំបាច់ ដែលផ្តល់ផលប្រយោជន៍ពិតប្រាកដសម្រាប់ឱ្យក្រសួង-ស្ថាប័នសម្រេចបេសកកម្មការងាររបស់ខ្លួន ដោយចៀសវាងឱ្យបាននូវការបង្កើតចំណាយមិនចាំបាច់ និងខ្ជះខ្ជាយ ។

- ឥណទានថវិកាដែលបានកាត់/សន្សំពីការផ្តល់ធានាចំណាយ និងការអនុវត្តកិច្ចលទ្ធកម្មនៃគម្រោងចំណាយរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ នឹងត្រូវបានបង្កកមិនអនុញ្ញាតឱ្យចំណាយបន្ថែម ឬធ្វើនិយ័តកម្មសម្រាប់បម្រើឱ្យចំណាយផ្សេងទៀតឡើយ វៀរលែងតែមានការពន្យល់ច្បាស់លាស់ពីសេចក្តីត្រូវការចាំបាច់បំផុតប៉ុណ្ណោះ ។

- មិនត្រូវស្នើសុំ និងផ្តល់ធានាចំណាយទៅលើការអនុវត្តនូវសកម្មភាពដែលនាំឱ្យមានការជ្រើសរើសមន្ត្រីថ្មី ឬមន្ត្រីជាប់កិច្ចសន្យានៅក្នុងឆ្នាំដែលកំពុងអនុវត្តដោយគ្មានការគ្រោងទុកក្នុងគម្រោងថវិកា ឬគ្មានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល ។

- តម្លៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសឥណទានថវិកាដែលបានផ្តល់ធានាចំណាយឡើយ ។ ចំពោះករណីដែលការអនុវត្តនីតិវិធីលទ្ធកម្មលើសពីឥណទានថវិកាដែលបានផ្តល់ពេលធានាចំណាយ ឬមាន

តម្រូវការជួរបរិមាណ ទំហំការងារយថាប្រភេទ ក៏ដូចជាគុណភាព, តាមសំណើរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ, អគ្គនាយកដ្ឋានថវិកា/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ឬអង្គភាពលទ្ធកម្ម ឬក្រុមលទ្ធកម្ម ត្រូវពិភាក្សាគ្នាដើម្បីរករកវិធានការដោះស្រាយប្រកបដោយតម្លាភាព និងស្របតាមនីតិវិធីជាធរមាន ។

នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្តដែលបានដាក់ចេញដូចខាងក្រោម÷

- ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម
- អនុក្រឹត្យលេខ ១៣ អនក្រ. បក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៩ ស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ១៦១៣ សហវ.ប្រក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ
- ប្រកាសលេខ ១៦១៤ សហវ.ប្រក ចុះថ្ងៃ ២៤ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីនីតិវិធីនៃការចុះការជម្រះនិងការផ្សព្វផ្សាយបញ្ជីខ្មៅ
- ប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម
- ប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- ប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីក្រមសីលធម៌លទ្ធកម្ម
- ប្រកាសលេខ ៩៨៨ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ
- ប្រកាសលេខ ២៤៩ សហវ. ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- ប្រកាសលេខ ១៨៦៦ សហវ. ប្រក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ស្ដីពីការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
- ប្រកាសអន្តរក្រសួងលេខ ៥៦៨ សហវ. ប្រក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ស្ដីពីការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ស្ដីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់
- ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៩ ស្ដីពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៩ ស្ដីពីការកក់ប្រាក់ធានាការដេញថ្លៃ និងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាក្នុងកិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០១៥ ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន ដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា
- សារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤ ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០០១ សហវ.អលសា ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្ដីពីការអនុវត្តច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- សេចក្ដីណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៩ ស្ដីពីនីតិវិធីសម្រាប់ធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ
- សេចក្ដីណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ស្ដីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់
- សេចក្ដីណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ស្ដីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម ។

- ដោយឡែក **ចំពោះការអនុវត្តចំណាយសម្រាប់ការទិញរថយន្ត** គឺត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចខាងក្រោម÷

• ដោយផ្អែកតាមស្មារតីនៃការចរចាថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបូកសរុបរួមនូវតម្រូវការទិញរថយន្តរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត រួមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានគ្រោងក្នុងឥណទានថវិកាឆ្នាំ ២០២២ និងទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយ ។ ដូចនេះ ក្រសួង-ស្ថាប័នមិនត្រូវបានអនុញ្ញាតឱ្យដាក់បញ្ចូលគម្រោងទិញរថយន្តផ្សេងទៀត ក្នុងផែនការលទ្ធកម្មឡើយ ។

• ផ្អែកតាមលទ្ធភាពឥណទានថវិកា និងតម្រូវការប្រើប្រាស់រថយន្តទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យក្រសួង-ស្ថាប័នមួយចំនួនលើកសំណើសុំទិញរថយន្តត្រឹមកម្រិតស្តង់ដារ (Standard Option) សម្រាប់ទាំងរថយន្ត Van និងទាំងរថយន្ត Pick-UP ។

• ក្រសួង-ស្ថាប័ន ត្រូវស្នើសុំគោលការណ៍ធានាចំណាយសម្រាប់ទិញរថយន្ត ដោយផ្អែកតាមចំនួនរថយន្តដែលទទួលបានគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាល និងមានភ្ជាប់ជាមួយនូវបញ្ជីប៉ាន់តម្លៃ និង យថាប្រភេទលម្អិតនៃរថយន្ត (Quotation and Technical Specification) ជាផ្លូវការពីក្រុមហ៊ុនផ្គត់ផ្គង់រថយន្តដែលបានទទួលសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ដោយត្រូវគិតបញ្ចូលពន្ធ និងអាករផ្សេងៗគ្រប់ប្រភេទ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យផ្តល់ធានាចំណាយ ព្រមជាមួយនឹងការផ្តល់ប្រាក់បុរេប្រទានជូនក្រសួង-ស្ថាប័នចំនួន ៤០% នៃទឹកប្រាក់ដែលផ្តល់ធានាចំណាយសម្រាប់កក់នៅពេលចុះកិច្ចសន្យា ។ ការទូទាត់បង្គ្រប់ត្រូវធ្វើឡើងបន្ទាប់ពីរថយន្តត្រូវបានប្រគល់ទទួលត្រឹមត្រូវតាមកិច្ចសន្យា ។ បន្ទាប់មក ក្រសួង-ស្ថាប័នត្រូវបោះផ្សាយអាណត្តិនិយ័តកម្មស្មើទឹកប្រាក់ដែលបានបុរេប្រទាន និងអាណត្តិបើកប្រាក់ទូទាត់បង្គ្រប់តាមកិច្ចសន្យា ដោយភ្ជាប់ជាមួយនូវឯកសារលិខិតយុត្តិការគ្រប់គ្រាន់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

• អនុញ្ញាតឱ្យអង្គភាពលទ្ធកម្មរបស់ក្រសួង-ស្ថាប័ន និងក្រុមលទ្ធកម្មនៃអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ, ដោយមិនមានកម្រិតទឹកប្រាក់, អនុវត្តវិធីសាស្ត្រចុះកិច្ចសន្យាផ្ទាល់ទិញរថយន្តជាមួយក្រុមហ៊ុនផ្គត់ផ្គង់រថយន្តណាដែលបានទទួលសិទ្ធិនាំចូលផ្តាច់មុខតែប៉ុណ្ណោះ ដោយមិនអនុញ្ញាតឱ្យចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនកណ្តាលឡើយ ។ ក្រសួង-ស្ថាប័ន ត្រូវអនុវត្តនីតិវិធីបន្តឱ្យបានសមស្របតាមគោលការណ៍លទ្ធកម្មសាធារណៈជាធរមាន ។

### ២.៤.៣- ការប្រគល់ទទួល(ទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា)

ការប្រគល់ទទួលទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា គឺជាដំណាក់កាលបន្ទាប់ពីក្រសួង-ស្ថាប័ន បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងឯកសារគតិយុត្ត និងលិខិតបទដ្ឋានពាក់ព័ន្ធ ។ ការប្រគល់ទទួល គឺពិនិត្យមើលពីភាពត្រឹមត្រូវ ទាំងមុខទំនិញ ឯកតា បរិមាណ តម្លៃ ប្រភព និងគុណភាព ព្រមទាំងផ្ទៀងផ្ទាត់មិនឱ្យលើសពីទឹកប្រាក់នៃការធានាចំណាយ និង



ឯកសារឡើងសាធារណៈ | https://t.me/oa_channel

មិនឱ្យខុសពីបទដ្ឋានបច្ចេកទេស និងយថាប្រភេទដែលបានជានាចំណាយ និងចុះកិច្ចសន្យាឡើយ ។ ដូចនេះ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រដ្ឋ មិនត្រូវបានអនុញ្ញាតឱ្យទទួលយក ទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាជាដាច់ខាត ប្រសិនបើមិនមានកិច្ចសន្យា ឬប្រសិនបើទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សាមិនត្រូវបានអនុវត្តបានគ្រប់ចំនួន និងត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាទេ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាននិត្យានុកូលភាពគ្រប់គ្រាន់ក្នុងការមិនទូទាត់ចំពោះករណីបែបនេះ ហើយក្រសួង-ស្ថាប័នដែលអនុវត្តខុសត្រូវទទួលខុសត្រូវលើភាពមិនប្រក្រតី តាមបទប្បញ្ញត្តិជាធរមាន ។

### ២.៤.៤- ការបើកប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ

បន្តអនុវត្ត និងពង្រីកនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) រួមទាំងការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមប្រព័ន្ធធនាគារតាមការសម្រេចរបស់រាជរដ្ឋាភិបាល ។ ដូច្នេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំឯកសារពាក់ព័ន្ធសម្រាប់ការអនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលា ដើម្បីធានាប្រសិទ្ធភាពនៃការបើកផ្តល់បៀវត្ស ឱ្យបានទៀងទាត់រៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ។ ចំពោះ ក្រសួង-ស្ថាប័នមួយចំនួនទៀត ដែលមិនទាន់អនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារបានពេញលេញនៅឡើយ ត្រូវពិនិត្យលទ្ធភាពក្នុងការពង្រីកការអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារនៅឆ្នាំ ២០២២ នេះ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬទាក់ទងផ្ទាល់ជាមួយគណៈកម្មការចម្រុះ ទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ ។

ដើម្បីធានាការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀតឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់នូវសារាចរលេខ ០៧ សរ, ចុះថ្ងៃពុធ ៥ កើត ខែមិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត របស់រាជរដ្ឋាភិបាល ។

ចំពោះចំនួនក្របខ័ណ្ឌ និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវតែពិនិត្យ និងអនុវត្តទៅតាមតារាងបៀវត្សដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលចេញដោយក្រសួងមុខងារសាធារណៈ និងរាល់ក្របខ័ណ្ឌគតិយុត្តដែលនៅមានជាធរមាន ជាពិសេសអនុក្រឹត្យសារាចរណែនាំ និងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា, ការត្រួតពិនិត្យឡើងវិញនូវចំនួន និងការគ្រប់គ្រងមន្ត្រីរាជការ, និងការកែសម្រួលប្រាក់បៀវត្សប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជាដើម ។

ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំអនុវត្តថវិកា ក្រសួង-ស្ថាប័នដើម ត្រូវតែធានាថា មន្ត្រីរាជការដែលទទួលបានការអនុញ្ញាតឱ្យផ្ទេរនេះ នៅបន្តទទួលបើកប្រាក់បៀវត្សនៅក្នុងក្របខ័ណ្ឌនៃក្រសួង-ស្ថាប័នដើម រហូតដល់ដំណាច់ឆ្នាំ ។ ទន្ទឹមនេះ ក្រសួង-ស្ថាប័នដែលអនុញ្ញាតឱ្យមន្ត្រីរាជការរូបនោះផ្ទេរចូល មិនត្រូវបានអនុញ្ញាតឱ្យស្នើសុំបន្ថែមឥណទានថវិកាសម្រាប់បើកបៀវត្សជូនមន្ត្រីរាជការដែលផ្ទេរចូលនៅក្នុងឆ្នាំអនុវត្តថវិកានោះទេ ប៉ុន្តែមានកាតព្វកិច្ចត្រូវគ្រោងប្រាក់បៀវត្សរបស់មន្ត្រីរាជការផ្ទេរចូល ឱ្យបានទាន់ពេលវេលានៃការរៀបចំថវិកាឆ្នាំបន្ទាប់ ។ ម្យ៉ាងទៀត ក្នុងករណីមានសំណើសុំផ្ទេរមន្ត្រីក្របខ័ណ្ឌពីមន្ទីរជំនាញរាជធានី-ខេត្ត មករដ្ឋបាលកណ្តាលនៃក្រសួង-ស្ថាប័ន, គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវលើកសំណើទៅក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាអំពីមុខងារដែលនាំឱ្យមានតម្រូវការផ្ទេរបុគ្គលិកពីមន្ទីរជំនាញរាជធានី-ខេត្តមករដ្ឋបាលកណ្តាលនៃក្រសួង-ស្ថាប័នក្នុងគោលដៅជួយដោះស្រាយបញ្ហាខ្វះខាតមន្ត្រីរាជការនៅផ្ទៃក្នុងក្រសួង-ស្ថាប័ននីមួយៗនោះ ។

**២.៤.៥-ការធ្វើចលនាឥណទានថវិកា**

ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួនតាមប្រកាសស្តីពីការបែងចែកចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានលម្អិតនៅក្នុងសៀវភៅថវិកា ។ ការធ្វើចលនាឥណទានថវិកា ត្រូវបានអនុញ្ញាតនៅដើមត្រីមាសទី ២ ក្រោយពីការអនុវត្តត្រីមាសមុនចប់សព្វគ្រប់ ។ ទោះជាយ៉ាងនេះក្តី ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានថវិកាមិនគ្រប់គ្រាន់ តែចាំបាច់ត្រូវចំណាយ ការធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវពន្យល់ឱ្យបានច្បាស់លាស់អំពីមូលហេតុ ជាពិសេសអំពីភាពចាំបាច់នៃការងារ និងអំពីភាពសល់ទំនេរនៃឥណទានថវិកា ដែលត្រូវផ្ទេរចេញបន្ទាប់ពីបណ្តាសកម្មភាពដែលបានគ្រោងត្រូវបានអនុវត្តរួច ។ ប៉ុន្តែ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្នើឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវគោរពឱ្យបាននូវមុខសញ្ញាឥណទានថវិកាដែលសំខាន់សម្រាប់សកម្មភាពគន្លឹះ ដែលបម្រើឱ្យគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមី ក្នុងករណីពិនិត្យឃើញថា មិនបានគោរពនូវគោលការណ៍ខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងមិនអនុញ្ញាតឱ្យមានការធ្វើចលនាឥណទានឡើយ ។

ដូចនេះ រាល់សំណើសុំនិយ័តភាពត្រូវធ្វើស្របតាមគោលការណ៍ស្តីពីការធ្វើចលនាឥណទានថវិកា ដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ។ ជាមួយគ្នានេះ *ក្រសួង-ស្ថាប័ន ទាំងរដ្ឋបាលកណ្តាល ទាំងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទ ចាំបាច់ត្រូវកត់សម្គាល់ផងដែរថា គោលការណ៍ណែនាំនេះ មានចែងអំពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការផ្ទេរឥណទាន និងនិយ័តកម្មនៃថវិកាកម្មវិធី ព្រមជាមួយនឹងការកំណត់នូវអនុគណនីចំណាយមួយចំនួន ដែលមិនត្រូវបានផ្តល់ប្រតិភូកម្មសិទ្ធិអំណាចក្នុងការផ្ទេរឥណទាន និងនិយ័តកម្មទេ រួមទាំងមុខចំណាយលើការប្រើប្រាស់អគ្គិសនី ទឹក សោហ៊ុយប្រៃសណីយ៍ ទូរគមនាគមន៍ សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា និងប្រាក់បំណាច់ម៉ោងបន្ថែម ហើយតម្រូវឱ្យស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ និងសម្រេច ។*



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

### ២.៤.៦-គោលការណ៍បន្ថែមសម្រាប់ការអនុវត្តចំណាយមិនមែនបន្ទុកបុគ្គលិក

ដើម្បីបង្កើនប្រសិទ្ធភាពចំណាយកម្រិតបច្ចេកទេស និង កម្រិតប្រតិបត្តិការ ជាពិសេស ដើម្បីសន្សំសំចៃចំណាយ ក្នុងបរិការណ៍នៃការបើកប្រទេសឡើងវិញលើគ្រប់វិស័យជាបន្តបន្ទាប់ ចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០២១ តាមគន្លងប្រក្រតីថ្មីនៃការរៀនរស់នៅជាមួយនឹងជំងឺកូវីដ-១៩ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំបន្ថែមដោយឡែក មួយចំនួនដូចខាងក្រោម÷

**(ក)- ចំណាយលើការរៀបចំ ពិធីបុណ្យ វគ្គបណ្តុះបណ្តាល, សន្និបាត, សន្និសីទ, សិក្ខាសាលា, ពិព័រណ៍ និងកិច្ចប្រជុំកម្រិតជាតិ និងកម្រិតអន្តរជាតិគ្រប់ប្រភេទ**

ក្នុងស្មារតីនៃការបង្កើនការសន្សំសំចៃខ្ពស់ មិនខ្ជះខ្ជាយថវិកាជាតិ គ្រប់ក្រសួង-ស្ថាប័ន ត្រូវរៀបចំតែពិធី/ព្រឹត្តិការណ៍ ដែលជាកាតព្វកិច្ចហើយខានមិនបាន និងជាសកម្មភាពចាំបាច់ដែលផ្តល់ផលចំណេញដល់ប្រទេសជាតិ ។ ពិធី/ព្រឹត្តិការណ៍ទាំងនោះ ត្រូវអនុលោម និងអនុវត្តតាមគោលការណ៍សំខាន់ៗ រួមមាន÷

- ✓ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់នូវចំណុច ៣.៧ នៃសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ១១៨៧ សជណ.សរ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៨ លើការរៀបចំពិធីជប់លៀង, ការទិញវត្ថុអនុស្សាវរីយ៍ និងការទិញសម្ភារៈផ្សេងៗបម្រើក្នុងពិធីគឺត្រូវមានលក្ខណៈសន្សំសំចៃខ្ពស់បំផុត,
- ✓ ការរៀបចំពិធីបុណ្យ, សន្និបាត, សន្និសីទ, សិក្ខាសាលាដែលមានទ្រង់ទ្រាយធំ, ពិព័រណ៍ និងកិច្ចប្រជុំក្នុងប្រទេសកម្រិតជាតិគ្រប់ប្រភេទ និងកម្រិតអន្តរជាតិកម្រិតអាស៊ាន តំបន់ និងពិភពលោក ចាំបាច់ត្រូវមានផែនការច្បាស់លាស់ និងត្រូវមានគ្រោងនៅក្នុងផែនការថវិកា ស្របតាមស្មារតីនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន,
- ✓ **ត្រូវអនុវត្តចំណាយរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ សន្និសីទកម្រិតជាតិ និងអន្តរជាតិ ត្រឹមកម្រិតឥណទានថវិកាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** និងត្រូវទូទាត់ជម្រះចំណាយឱ្យអស់ក្នុងឆ្នាំថវិកានីមួយៗ ដោយមិនអនុញ្ញាតឱ្យយោងទៅទូទាត់ និងប្រើឥណទានថវិកាឆ្នាំបន្ទាប់ឡើយ ព្រមទាំងត្រូវជានាការចូលរួមរបស់មន្ត្រី ក្នុងចំនួនចាំបាច់ និងតិចបំផុត ក្នុងការទ្រទ្រង់ដំណើរការរៀបចំ ។ ក្នុងករណីមានត្រូវការចាំបាច់ ជាក់ស្តែងក្នុងការអនុវត្តសកម្មភាពបន្ថែមដែលនាំឱ្យមានចំណាយកើនឡើង ត្រូវលៃលកប្រើប្រាស់ឥណទានថវិកាផ្ទៃក្នុងដែលមានក្នុងឆ្នាំអនុវត្តថវិកា,
- ✓ ជ្រើសរើសការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ សន្និសីទកម្រិតជាតិ និងអន្តរជាតិ នៅទីតាំងដែលនៅជិតបំផុត ដើម្បីកាត់បន្ថយចំណាយដែលមិនចាំបាច់ ជាពិសេសចំណាយលើសោហ៊ុយបេសកកម្ម,

- ✓ កាត់បន្ថយចំណាយ និងសកម្មភាពដែលមានលក្ខណៈប្រមូលផ្តុំអ្នកចូលរួមមិនអាចបំពេញបាន តាមវិធានសុខាភិបាល ដូចជា ពិធីជប់លៀង ឬបដិសណ្ឋារកិច្ច ជាដើម,
- ✓ ត្រូវចៀសវាងអនុវត្តសកម្មភាពដោយមិនមានស្នើសុំគោលការណ៍ចំណាយជាមុន ដែលនាំឱ្យមិនមានឥណទានថវិកាគ្រប់គ្រាន់សម្រាប់ទូទាត់ ។ ក្នុងករណីមិនអនុលោមតាមគោលការណ៍កំណត់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាននិត្យានុកូលភាពគ្រប់គ្រាន់ ក្នុងការមិនពិនិត្យទូទាត់ថវិកាជូនក្រសួង-ស្ថាប័ន ចំពោះសំណើពាក់ព័ន្ធនឹងការងារនេះឡើយ ។ ការរៀបចំពិធី/ព្រឹត្តិការណ៍នានាជាលក្ខណៈអន្តរជាតិ រួមទាំងការទទួលភ្ញៀវអន្តរជាតិផង ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍បដិការ ប៉ុន្តែត្រូវស្របតាមលទ្ធភាពនៃថវិការបស់ជាតិផងដែរ,
- ✓ បន្តស្មារតីសន្សំសំចៃខ្ពស់ និងបង្កើនប្រសិទ្ធភាពចំណាយថវិកាជាតិ ដោយពិនិត្យលទ្ធភាពក្នុងការបន្តអនុវត្តតាមប្រព័ន្ធនិម្មិត (Online) ។ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ទាំងនៅរដ្ឋបាលថ្នាក់ជាតិ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អាចរៀបចំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ សន្និសីទកម្រិតជាតិ និងអន្តរជាតិដោយផ្ទាល់ ក្នុងករណីដែលមានតម្រូវការក្នុងការ-ពិភាក្សាគ្នាល្អិតល្អន់ដើម្បីឈានដល់ការសម្រេចចិត្តណាមួយ ឬពាក់ព័ន្ធនឹងការបណ្តុះបណ្តាលដែលទាមទារឱ្យមានការបង្ហាញជូនសិក្ខាកាមដោយផ្ទាល់,
- ✓ មុខសញ្ញាចំណាយមួយចំនួនដែលមិនមានតម្រូវការចាំបាច់ ជាអាទិ៍ ការបោះពុម្ពឯកសារ សម្ភារៈ ការជួលទីតាំង ការរៀបចំកន្លែង អាហារជប់លៀង បដិសណ្ឋារកិច្ច វត្ថុអនុស្សាវរីយ៍ និងចំណាយផ្សេងៗ មិនត្រូវបានអនុញ្ញាតឱ្យលើកគម្រោងចំណាយ តាមគោលការណ៍នៃប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំ វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងអន្តរជាតិទាំងស្រុងឡើយ លើកលែង តែចំណាយរបស់ក្រុមការងារ ឬលេខាធិការដ្ឋានដឹកនាំកិច្ចប្រជុំផ្ទាល់ដែលតម្រូវឱ្យមានចំណាយទាំងនេះ ។

**(ខ)- ប្រាក់បេសកកម្មក្រៅប្រទេស**

កន្លងមកនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើនប្រាក់បេសកកម្មក្រៅប្រទេសជូនដល់មន្ត្រីរាជការ ដើម្បីធានាបាននូវការសន្សំសំចៃខ្ពស់បំផុត ដោយចៀសវាងឱ្យបាននូវការចំណាយលើបេសកកម្មក្រៅប្រទេស ដែលមិនរួមចំណែកដល់ការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំដល់គ្រប់ក្រសួង-ស្ថាប័នធ្វើអាទិភាវូបនីយកម្មបេសកកម្មក្រៅប្រទេស ដោយពិនិត្យឡើងវិញអំពីភាពចាំបាច់/សារប្រយោជន៍ ឬផលប្រយោជន៍ដែលកម្ពុជាទទួលបានពីការចូលរួមនោះ ក្នុងការសម្រេចគោលដៅអាទិភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ចំនួនដងនៃបេសកកម្ម និងទំហំនៃគណៈប្រតិភូឱ្យនៅចំនួនអប្បបរមា និងពាក់ព័ន្ធជាចាំបាច់ ។ ក្រសួង-ស្ថាប័នត្រូវប្រកាន់ ស្មារតីហ៊ានបដិសេធនូវការអញ្ជើញ



ឯកសារឡើងវិញដោយ: | https://t.me/oa_channel

បេសកកម្មក្រៅប្រទេសទាំងឡាយណា ដែលផ្តល់ប្រយោជន៍តិចតួច ឬមិនសូវមានប្រយោជន៍ ឬមិនមានប្រយោជន៍ ដល់ក្រសួង-ស្ថាប័ន ហើយដែលយើងត្រូវចេញសោហ៊ុយខ្ពួនឯង ។ **ក្រសួង-ស្ថាប័នត្រូវបំពេញបេសកកម្មក្រៅប្រទេស ដោយផ្អែកជាចាំបាច់លើភាពទំនេរនៃឥណទានថវិកាជាមុនរបស់ក្រសួង-ស្ថាប័ន និងមិនមែនជាកម្មវត្ថុនៃការស្នើសុំឥណទានបន្ថែម ឬធ្វើចលនាឥណទានថវិកានោះទេ** ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមគូសបញ្ជាក់ថា **ចំណាយបេសកកម្មក្រៅប្រទេសត្រូវធ្វើឡើងតែក្នុងឥណទានថវិកាដែលបានវិភាជប្រចាំឆ្នាំ** មានផែនការច្បាស់លាស់ជាមុន និងត្រូវមានប្រព័ន្ធរបាយការណ៍ដែលបង្ហាញពីសារប្រយោជន៍នៃបេសកកម្មទាំងនោះ ។ ជារួម, ក្រសួង-ស្ថាប័ន ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ តាម**សារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៦ សរណន ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីគោលការណ៍អនុវត្តចំណាយលើសោហ៊ុយបេសកកម្មក្រៅប្រទេស** ដែលមានខ្លឹមសារ ដូចខាងក្រោម÷

- ✓ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តចំណាយបេសកកម្មនៅក្រៅប្រទេសត្រឹមកម្រិតឥណទានអតិបរមាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវទូទាត់ឱ្យអស់ក្នុងឆ្នាំថវិកានីមួយៗ ហើយមិនត្រូវអនុវត្តចំណាយបេសកកម្មនៅទៅក្រៅប្រទេស ដោយមិនមានឥណទានថវិកាសម្រាប់ទូទាត់នោះទេ ។
- ✓ បន្តស្មារតីសន្សំសំចៃខ្ពស់លើចំណាយថវិកាជាតិ ដោយពិនិត្យលទ្ធភាពក្នុងការបន្តអនុវត្តតាមប្រព័ន្ធនិម្មិត ឬប្រើប្រាស់មន្ត្រីនៅប្រចាំប្រទេសនោះ ដើម្បីចូលរួមជំនួស ។ ការចុះបេសកកម្មទៅក្រៅប្រទេសតែក្នុងករណីចាំបាច់ដែលមិនអាចអនុវត្តតាមប្រព័ន្ធនិម្មិតបាន ឬមិនអាចប្រើប្រាស់មន្ត្រីនៅប្រចាំប្រទេសនោះដើម្បីចូលរួមជំនួសបាន ។
- ✓ មិនអនុញ្ញាតឱ្យអនុវត្តចំណាយមុន លើចំណាយបេសកកម្មទៅក្រៅប្រទេស ដោយមិនមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល និង/ឬពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។ ក្នុងករណីនៅតែបន្តមានក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលខុសត្រូវក្នុងការដោះស្រាយចំណាយនេះដោយផ្ទាល់ក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់ខ្លួន ។
- ✓ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវណែនាំដល់ប្រធានអង្គភាព និងមន្ត្រីក្រោមឱវាទ ឱ្យចាត់វិធានការរឹតបន្តឹងការគ្រប់គ្រងចំណាយសោហ៊ុយបេសកកម្មក្រៅប្រទេសឱ្យបានម៉ឺងម៉ាត់ និងក្នុងស្មារតីសន្សំសំចៃខ្ពស់ ។

**(គ)- ប្រាក់បេសកកម្មក្នុងប្រទេស**

ដូចគ្នាដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើនប្រាក់បេសកកម្មក្នុងប្រទេសជូនដល់មន្ត្រីរាជការដើម្បីធានាភាពថ្លៃថ្នូរ និងការអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ថែមទៀត នៅក្នុងអំឡុងពេលបំពេញបេសកកម្ម តាមបណ្តារាជធានី-ខេត្ត ទូទាំងប្រទេស ។ ក្នុងន័យនេះ **ក្រសួង-ស្ថាប័ន និងអង្គភាពចំណាយ**

ពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តចំណាយត្រឹមកម្រិតឥណទានដែលមានក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងអនុវត្តប្រកបដោយតម្លាភាពនូវចំនួនថ្ងៃ និងចំនួនមន្ត្រីចុះបេសកកម្មពិតប្រាកដ ត្រូវលុបបំបាត់ឱ្យបាននូវការបំប៉ោងចំនួនថ្ងៃ និងចំនួនមន្ត្រីចុះបេសកកម្ម លើសពីការអនុវត្តជាក់ស្តែង ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវការរៀបចំកម្មវិធីនៅតាមរាជធានី-ខេត្ត ដើម្បីគោលដៅទទួលបានប្រាក់បេសកកម្ម ឬក៏យកបេសកកម្ម ធ្វើជាត្រីមុខ ។

ស្របតាមសារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការទូទាត់ត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីរាជការ គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវបើកផ្តល់ប្រាក់បេសកកម្មជូនដល់មន្ត្រីរាជការដែលមានភារកិច្ចបំពេញបេសកកម្មការងារ ទាំងនៅក្នុងប្រទេស និងទៅក្រៅប្រទេស ដោយបង្វែរត្រង់ចូលគណនីប្រាក់បៀវត្សរបស់មន្ត្រីរាជការផ្ទាល់តែម្តង ដោយមិនអនុញ្ញាតឱ្យបើកជាសាច់ប្រាក់ផ្ទាល់នោះឡើយ ។

**(ឃ)- ចំណាយទិញឧបករណ៍ និងសម្ភារៈថែទាំសុខភាព**

ចំណាយសម្រាប់ទិញឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ និងសម្ភារការពារពាក់ព័ន្ធមួយចំនួនទៀត បម្រើដល់ការការពារសុខភាព, ថែរក្សាអនាម័យ និងកម្ចាត់មេរោគ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រោងក្នុងអនុគណនី ៦០០៧៨ (សម្ភារៈបរិក្ខារថែទាំសុខភាពផ្សេងៗ) និងត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ១០០% លើកលែងតែ មន្ទីរពេទ្យ និងមណ្ឌលសុខភាពដែលមាននីតិវិធីអនុវត្តដោយឡែក ។

**២.៥-ការអនុវត្តថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ឆ្នាំ ២០២២ គឺជាឆ្នាំទី ៧ នៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS ដំណាក់កាលទី ៣ ។ ប្រព័ន្ធនេះ ត្រូវបានរៀបចំដោយអនុលោមទៅតាមស្តង់ដារឧត្តមានុវត្តន៍ទាំងមូលដ្ឋានគណនេយ្យ ទាំងប្រតិបត្តិការហិរញ្ញវត្ថុ ។ នៅក្នុងដំណាក់កាលអនុវត្តថវិកាប្រតិបត្តិការ ចំណូល-ចំណាយថវិកាជាតិ រួមទាំងការទូទាត់ទាំងអស់ត្រូវធ្វើឡើងតាម FMIS ដោយមានការកត់ត្រា, តាមដាន, និងគ្រប់គ្រងដោយស្វ័យប្រវត្តិ ។ ដូចនេះ ដើម្បីឱ្យការទូទាត់ចំណូល-ចំណាយថវិកាជាតិ អាចធ្វើទៅបានចាំបាច់ត្រូវមានឥណទានថវិកានៅក្នុងប្រព័ន្ធ ហើយទន្ទឹមនេះ រាល់ប្រតិបត្តិការចលនាឥណទានថវិកា (ទាំងការផ្ទេរ និងការបន្ថែមឥណទានថវិកា) ដែលធ្វើឡើងនៅគ្រប់អង្គភាពអនុវត្តថវិកាទាំងអស់ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ ។

ក្នុងគោលដៅខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការណែនាំដោយឡែកបន្ថែមទៀត អំពីនីតិវិធី និងតម្រូវការពាក់ព័ន្ធផ្សេងៗ ដើម្បីស្នើសុំកិច្ចសហប្រតិបត្តិការ និងកិច្ចសហការពីគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ។

**៣. ការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការធ្វើរបាយការណ៍**

គ្រប់ក្រសួង-ស្ថាប័ន ត្រូវពង្រឹងសមត្ថភាព និងតួនាទីរបស់អគ្គនាយកដ្ឋានសវនកម្ម/នាយកដ្ឋានសវនកម្មផ្ទៃក្នុង/អគ្គាធិការដ្ឋានរបស់ខ្លួន ជាមួយគ្នានឹងការពង្រឹងសមត្ថភាព និងតួនាទីរបស់អគ្គាធិការដ្ឋាននៃក្រសួង

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការត្រួតពិនិត្យការអនុវត្តថវិកាជាតិ ជាពិសេសការត្រួតពិនិត្យជាក់ស្តែងរាល់ការប្រមូលចំណូល និងការអនុវត្តចំណាយថវិកាជាតិ ដោយវាយតម្លៃនូវការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ/របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំតាមបណ្តាក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ដើម្បីរួមចំណែកទប់ស្កាត់កំហុសឆ្គង និងពង្រឹងអភិបាលកិច្ចក្នុងការគ្រប់គ្រង និងការអនុវត្តហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាដើម្បីបង្កើននូវប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

ដើម្បីបង្កើនគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ជាពិសេសដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ឱ្យបានទៀងទាត់ទៅតាមគំរូដែលបានផ្ញើជូន និងទៅតាមកាលបរិច្ឆេទដូចខាងក្រោម÷

- **របាយការណ៍ហិរញ្ញវត្ថុ**
    - របាយការណ៍ប្រចាំខែ *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់* ។
    - របាយការណ៍ប្រចាំត្រីមាស *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែនៅដើមត្រីមាសបន្ទាប់* ។
    - របាយការណ៍ឆមាសទី ១ *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី ២ នៃខែ កក្កដា* ។
    - របាយការណ៍ប្រចាំឆ្នាំបឋម *ត្រូវផ្ញើយ៉ាងយឺតបំផុតត្រឹម ខែ មករា ឆ្នាំ ២០២៣ មកអគ្គនាយកដ្ឋានថវិកា និងត្រូវផ្ញើរបាយការណ៍សម្រេចចុងក្រោយមកអគ្គនាយកដ្ឋានរតនាគារជាតិយ៉ាងយឺតបំផុតត្រឹមខែ មីនា ឆ្នាំ ២០២៣* ។

- **របាយការណ៍សមិទ្ធកម្ម**

ដើម្បីជាមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បូកសរុប និងតាមដានការអនុវត្តថវិកាកម្មវិធី និងធ្វើរបាយការណ៍បូកសរុបអំពីសមិទ្ធកម្ម, គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តក្រោមឱវាទទាំងអស់ ដែលអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំទាំងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម ទៅតាមគំរូ និងកាលបរិច្ឆេទ ដូចមានចែងក្នុង **គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី** ។ ផ្អែកតាមប្រកាសលេខ ៥៥៤ សហវ. ប្រក ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា របាយការណ៍សមិទ្ធកម្មត្រូវធ្វើឡើងតាមការិយបរិច្ឆេទថ្មី ដូចខាងក្រោម÷

- ផ្តល់តារាងសូចនាករលទ្ធផលក្នុងឆ្នាំ ឬធាតុចេញ (Output) និងលទ្ធផលចុងក្រោយ (Outcome) ដែលគ្រោងនឹងសម្រេចឱ្យបាននៅឆ្នាំ ២០២២ (តាមទម្រង់ដែលបានកំណត់) ស្របទៅតាម

កញ្ចប់ថវិកាដែលបានវិភាជ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនិងនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា) *ឱ្យបានមុនដំណាច់ខែ មករា ឆ្នាំ ២០២២*

- របាយការណ៍សមិទ្ធកម្មប្រចាំឆមាស (តាមទម្រង់ដែលមានភ្ជាប់) កម្រិតចង្កោមសកម្មភាព និង/ឬ កម្រិតអនុកម្មវិធី ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនិងនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា) *យ៉ាងយូរបំផុត ២០ ថ្ងៃ បន្ទាប់ពីបញ្ចប់ការអនុវត្តនៃឆមាសទី ១*
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ (តាមទម្រង់ដែលមានភ្ជាប់) ពីកម្រិតចង្កោមសកម្មភាពដល់កម្រិតកម្មវិធី ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនិងនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា, និងអគ្គនាយកដ្ឋានរតនាគារជាតិ) *យ៉ាងយូរបំផុតត្រឹមខែ មីនា នៃឆ្នាំបន្ទាប់ពីឆ្នាំ ២០២៣* ។

ទន្ទឹមនេះ ផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុ/របាយការណ៍សមិទ្ធកម្មអនុវត្តខាងលើ ដើម្បីបង្កើនប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើអធិការកិច្ចហិរញ្ញវត្ថុជាក់ស្តែង តាមការចាំបាច់លើការអនុវត្តថវិកាកម្មវិធីរបស់គ្រប់ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញ រាជធានី-ខេត្តក្រោមឱវាទទាំងអស់ ។

## ៤. នីតិវិធីនៃការគ្រប់គ្រង និងអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលបំណងធ្វើឱ្យកាន់តែប្រសើរនូវការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ និងភាពឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។ ផ្អែកតាមខ្លឹមសារនៃលិខិតលេខ ២៣៩៨ សហវ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុវត្តតាមក្របខ័ណ្ឌគតិយុត្តថ្មី និងតាមនីតិវិធីហិរញ្ញវត្ថុថ្មីជាធរមាន ។ នីតិវិធីគ្រប់គ្រង និងអនុវត្តថវិកា ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវផ្អែកលើក្របខ័ណ្ឌគតិយុត្ត ដែលបានដាក់ចេញដូចខាងក្រោម÷

- ព្រះរាជក្រឹត្យលេខនស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យ លេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- អនុក្រឹត្យលេខ ០១៥ អនក្រ. បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៩ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- ប្រកាសលេខ ០១៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរជ្ជទេយ្យបុរេប្រទាន និងគណនេយ្យរជ្ជទេយ្យចំណូលរបស់គ្រឹស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹស្ថានសាធារណៈរដ្ឋបាល និង
- លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត ដែលនឹងត្រូវដាក់ឱ្យអនុវត្តសម្រាប់បម្រើកិច្ចដំណើរការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ។

ទន្ទឹមនេះ ដើម្បីបង្កើនប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ ការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវត្រួតពិនិត្យ វាយតម្លៃដោយសវនកម្ម/អធិការកិច្ចផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័នសាមី និងធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការចាំបាច់ ។

## ៥. វិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវពង្រឹងតាមវិធានការដូចខាងក្រោម÷

- ជំរុញរៀបចំកម្មវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីដាក់ឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋប្រើប្រាស់ក្នុងឆ្នាំ ២០២១

- ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់និងលិខិតបទដ្ឋានទាំងឡាយ ពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងនីតិបុគ្គលសាធារណៈ ត្រូវទទួលខុសត្រូវរៀបចំតារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០២១ ឱ្យបានតាមពេលកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបំពេញតួនាទីជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយទទួលខុសត្រូវខ្ពស់ក្នុងការសម្រេចឱ្យបានតាមការកំណត់ក្នុងការរៀបចំតារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០២១ នៅថ្នាក់ក្រោមជាតិ ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិ ចូលក្នុងបញ្ជីសារពើភ័ណ្ឌ

- បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយសវនកម្ម/អធិការកិច្ចផ្ទៃក្នុងរបស់ខ្លួនតាមការចាំបាច់

-បន្តពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការគ្រប់គ្រង ការប្រើប្រាស់ និងកាចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋក្រោមឱវាទ តាមការចាំបាច់ ។

## ៦. វិធានការរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា

ក្នុងករណីដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តថវិកានឹងមិនអាចសម្រេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នត្រូវមានវិធានការដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងសហការជាមួយក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា ដើម្បីបន្តបង្កើនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានពីខាងក្រៅ និងរក្សាឱ្យបានស្ថិរភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅកម្ពុជា,

- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការតាមដានការអនុវត្តថវិកា និងសកម្មភាពការងាររបស់ខ្លួនជាប្រចាំ និងអនុវត្តប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ច និងត្រៀមវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាព ដោយចៀសវាងប៉ះពាល់ដល់សកម្មភាពអាទិភាពខ្ពស់ ក្នុងករណីមានការតម្រឹមចំណាយជាយថាហេតុ,

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យ លើការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតម្រូវក្នុងករណីចាំបាច់ ។

## ៧. វិធានការលើកកម្ពស់តម្លាភាពនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

ក្នុងការលើកកម្ពស់តម្លាភាពនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងរៀបចំបង្ហោះនៅលើគេហទំព័រនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវឯកសារពាក់ព័ន្ធនឹងច្បាប់ថវិកាឆ្នាំ ២០២២ រួមទាំងការរៀបចំឯកសារថវិកាសង្ខេប (Budget In Brief) និងតារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលប្រចាំខែ ដើម្បីផ្តល់ជាព័ត៌មានដល់សាធារណជនទូទៅ ឱ្យបានយល់អំពីគោលដៅនៃការប្រើប្រាស់ថវិកាឆ្នាំ ២០២២ ។ ទន្ទឹមនេះ ក្រសួង-ស្ថាប័ន ក៏ត្រូវផ្សព្វផ្សាយនៅលើគេហទំព័ររបស់ខ្លួនផងដែរនូវរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន រួមមាន÷ គោលបំណងគោលនយោបាយ និងកម្មវិធីដែលក្រសួងបានដាក់អនុវត្ត និងការបែងចែកថវិកាទៅតាមរចនាសម្ព័ន្ធកម្មវិធី តាមគំរូតារាងជូនភ្ជាប់ ។

## ៨. ទណ្ឌកម្មនិងការទទួលខុសត្រូវចំពោះមន្ត្រីសាធារណៈ

មន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវការអនុវត្តអភិបាលកិច្ចល្អឱ្យមានប្រសិទ្ធភាពខ្ពស់ តាមវិធានការច្បាប់ និងលិខិតបទដ្ឋានជាធរមានដូចខាងក្រោម÷



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

- ចាត់វិធានការរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈណាដែលបានប្រព្រឹត្តនូវកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទទួលទោសតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងទទួលតាមកម្រិតទោសទណ្ឌនៃក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិព្រហ្មទណ្ឌ,

- គ្រប់មន្ត្រីសាធារណៈ ត្រូវហ៊ានទទួលខុសត្រូវនូវកំហុសឆ្គងដែលបានប្រព្រឹត្ត និងកំពុងអនុវត្តប្រតិបត្តិការលើការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ ទៅតាមបទដ្ឋានគតិយុត្ត នៃវិន័យហិរញ្ញវត្ថុសាធារណៈ សារាចរ ប្រកាស អនុក្រឹត្យ ដែលបានណែនាំដោយរាជរដ្ឋាភិបាល,

- ចាត់វិធានការតាមវិន័យរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈ ក្រោយពីបានរកឃើញនូវសកម្មភាពដែលបានធ្វើឱ្យបាត់បង់ប្រាក់កាស ឬខូចខាតទ្រព្យសម្បត្តិសាធារណៈ ទោះតម្លៃនៃការបាត់បង់ ឬខូចខាតរួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬខូចខាតបានក្លាយជាបំណុលសាធារណៈក្តី មន្ត្រីសាធារណៈនោះត្រូវសង និងត្រូវបង់ជាសាច់ប្រាក់ចូលថវិការដ្ឋវិញ ។

## ៩. សេចក្តីសន្និដ្ឋាន

ថវិកាឆ្នាំ ២០២២ ត្រូវបានគិតគូរ និងរៀបចំឡើងក្នុងបរិការណ៍ដែលកម្ពុជា ក៏ដូចជាពិភពលោកទាំងមូលកំពុងស្ថិតនៅកណ្តាលនៃវិបត្តិជំងឺកូវីដ-១៩ នៅឡើយ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលតម្រង់ការប្រើប្រាស់ធនធានដើម្បី, ម្ខាង, ទ្រទ្រង់ដល់កិច្ចខិតខំប្រយុទ្ធនឹងជំងឺកូវីដ-១៩, ម្ខាងទៀត, ស្តារ និងជំរុញសេដ្ឋកិច្ចឱ្យបន្តស្ថិតនៅលើគន្លងនៃកំណើនខ្ពស់ និងរស់រវើកឡើងវិញ ព្រមទាំងស្តារជីវភាពរបស់ប្រជាជនទូទៅក៏ដូចជាដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗ នៃ **កម្មវិធីនយោបាយ, យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣** ពិសេសការជំរុញល្បឿននៃការអនុវត្តកិច្ចការកែទម្រង់លើគ្រប់វិស័យក្នុងឆ្នាំ ២០២២ ដែលជាឆ្នាំទី ៤ នៃអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា សំដៅកសាងមូលដ្ឋានគ្រឹះថ្មីៗបន្ថែម ក្នុងដំណើរឈានឆ្ពោះទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា ដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទនភាពជាតិ មានអនាគតដ៏រុងរឿងភ្លឺស្វាង ត្រចះត្រចង់ និងជារដ្ឋអធិបតេយ្យមួយរឹងមាំ ដែលគោរពខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ ។

សរុបមក, ថវិកាឆ្នាំ ២០២២ ត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង, ទាំងក្នុង និងក្រៅប្រទេស, សំដៅបន្តការពារអាយុជីវិត លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនពលរដ្ឋ ព្រមទាំងស្តារ និងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជា ទន្ទឹមនឹងការរៀនរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ហើយអាចប្រសិទ្ធនាមបានថាជា **"ថវិកាសម្រាប់បន្តការប្រយុទ្ធប្រឆាំង និងការកសាងសមត្ថភាពរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លង**

ប្រក្រតីថ្មី ដើម្បីបន្តប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន **ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ**" ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ដែលបានលើកឡើងខាងលើ ពិសេសការបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងផ្តល់លទ្ធផលជាក់ស្តែង ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៥ យ៉ាង គឺ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" ។ ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ សូមមេត្តាផ្តល់ការគាំទ្រ និងចូលរួមអនុវត្តដោយសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងឈរលើគោលការណ៍តម្កល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**__កន្លែងទទួល៖__**
- អគ្គលេខាធិការដ្ឋានក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់រាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
-រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel